**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

លេខ: ១៤៣/១៩ អ.ជ.ប.គ.ញ

ថ្ងៃ ពុធ ៩រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៩

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ន៩មាស (៩ខែ) និងទិសដៅការងារ ត្រីមាសទី៤ ឆ្នាំ២០១៩

(ថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩)

អនុវត្តតាមផែនការជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៤ ក៏ដូចជា គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ពិសេសរាល់ទិសដៅដែលបានដាក់ចេញសម្រាប់ឆ្នាំ២០១៩ ដោយសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៨ និងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួង ស្ថាប័ន អង្គភាព និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ជាសមាជិក និងជាសេនាធិការ បានខិតខំប្រឹងប្រែងអនុវត្តការងារក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីរួមចំណែកថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការអភិវឌ្ឍសង្គម ធនធានមនុស្សប្រកបដោយសក្តានុពលភាពសម្រាប់ជាតិ ហើយទទួលបាននូវលទ្ធផលជាក់ស្តែង ដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

### ក. សភាពការណ៍គ្រឿងញៀនអន្តរជាតិ និងតំបន់ [1] ៖

ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៩ នេះ តាមរបាយការណ៍របស់ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC)ឆ្នាំ២០១៨ កិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន (ADEC-24) លើកទី២៤ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីគ្រឿងញៀន(ASOD)លើកទី៤០ និងកិច្ចប្រជុំអន្តរជាតិនានា ស្តីពីគ្រឿងញៀន បានបង្ហាញថា តម្រូវការគ្រឿងញៀនប្រភេទមេតំហ្វេតាមីន(ពិសេសមេតំហ្វេតាមីនក្រាមម្សៅ) មានការកើនឡើងខ្លាំង ទាំងនៅក្នុងកម្រិតតំបន់ និងលើពិភពលោក ។ សកម្មភាពនៃការផលិតគ្រឿងញៀនក្នុងតំបន់ ភាគច្រើនស្ថិតក្នុងក្រុមឧក្រិដ្ឋជនដែលប្រដាប់ដោយអាវុធ និងទទួលមូលនិធិពីក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិ ទន្ទឹមនោះ សកម្មភាពផលិតអាភៀនមួយចំនួនបានផ្លាស់ប្តូរទៅជាការផលិតគ្រឿងញៀនសំយោគ ដែលធ្វើឱ្យបរិមាណគ្រឿងញៀនសំយោគដែលបង្ក្រាបបាន មានការកើនឡើងជាបន្តបន្ទាប់ ហើយតម្លៃគ្រឿងញៀនសំយោគក៏មានការធ្លាក់ចុះ ចាប់តាំងពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ។ ជារួម ចរន្តនៃការដាំដុះរុក្ខជាតិញៀន ការផលិត និងការចរាចរគ្រឿងញៀន នៅលើពិភពលោកពុំមានការថយចុះនោះទេ ពិសេសរុក្ខជាតិញៀនកញ្ឆានៅតែបន្តមានការដាំដុះ ផលិត និងប្រើប្រាស់ច្រើនជាងគេ ។ ដោយឡែក នៅអាមេរិកខាងត្បូងការផលិតអាភៀនឃើញថាមានការកើនឡើង និងស្របពេលជាមួយគ្នានេះ ដំណាំកូកាក៏នៅតែបន្តមានការដាំដុះ ។ ក្រុមឧក្រិដ្ឋជនអាហ្វ្រិកខាងលិច នៅតែជាក្រុមដួញដូរគ្រឿងញៀនដ៏ធំដែលធ្វើសកម្មភាពនៅតាមព្រលានយន្តហោះ។ ទន្ទឹមនោះក៏

[1] សភាពការណ៍គ្រឿងញៀនអន្តរជាតិ និងក្នុងតំបន់ ដកស្រង់ពីរបាយការណ៍UNODC កិច្ចប្រជុំ ADEC-24 និងកិច្ចប្រជុំអន្តរជាតិនានាស្តីពីគ្រឿងញៀន

មានការកើនឡើងខ្លាំងនូវការចរាចរប្រភេទគ្រឿងញៀនមេតំហ្វេតាមីន ពិសេសមេតំហ្វេតាមីនក្រាមម្សៅ(ICE) ចេញពីតំបន់ត្រីកោណមាសឆ្លងកាត់ បណ្តាប្រទេសក្នុងអនុតំបន់ទន្លេមេគង្គ ទៅកាន់ប្រទេសដែលមានតម្រូវការ និង ទីផ្សារប្រើប្រាស់គ្រឿងញៀនខ្ពស់ ។

ជាមួយគ្នានេះ កិច្ចប្រជុំទាំងអស់ខាងលើ ក៏បានវាយតម្លៃពីស្ថានភាពគ្រឿងញៀននាពេលខាងមុខថា ការផលិតគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ពិសេសមេតំហ្វេតាមីនក្រាមម្សៅ(ICE) នឹងកើនឡើងខ្លាំងថែមទៀតនៅក្នុងតំបន់ភាគខាងជើងប្រទេសមីយ៉ាន់ម៉ា ដោយសារមានការលួចនាំចូលសារធាតុគីមីផ្សំគ្រឿងញៀន ទៅកាន់តំបន់នោះមានការកើនឡើងខ្ពស់ និងមិនមានការត្រួតពិនិត្យឲ្យបានដិតដល់ ។ ការចរាចរឆ្លងកាត់ព្រំដែនប្រទេសឡាវនូវគ្រឿងញៀនប្រភេទមេតំហ្វេតាមីនខាងលើនេះ នឹងអាចមានកំណើនខ្ពស់ជាងមុន ដោយសារនៅតាមបណ្តាយព្រំដែនថៃ-មីយ៉ាន់ម៉ា បង្កើនការរឹតបន្តឹងការត្រួតពិនិត្យដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទាំងពីរ ។ ម្យ៉ាងវិញទៀត សមត្ថកិច្ចក៏បានរកឃើញផងដែរថា សកម្មភាពប្រតិបត្តិការសាច់ប្រាក់របស់ក្រុមឧក្រិដ្ឋជន តាមរយៈកាស៊ីណូក្នុងការចរាចរ និងជួញដូរគ្រឿងញៀននៅក្នុងតំបន់ គឺមានការកើនឡើង ហើយវិធីសាស្ត្រក្នុងការលួចលាក់ធ្វើសកម្មភាពក៏មានការប្រែប្រួលកាន់តែស្មុគស្មាញឡើង ។

**ខ. សភាពការណ៍គ្រឿងញៀនកម្ពុជា :**

ដោយសារសកម្មភាពផលិត ជួញដូរគ្រឿងញៀនលើពិភពលោក និងនៅក្នុងតំបន់ នៅតែមានស្ថានភាពប្រែប្រួលកើនឡើងឥតឈប់ឈរ ហើយល្បិចកលរបស់ក្រុមឧក្រិដ្ឋជនកាន់តែស្មុគស្មាញ ដូចបានរៀបរាប់ខាងលើធ្វើឲ្យកម្ពុជានៅតែបន្តទទួលរងនូវនិន្នាការគំរាមកំហែងថ្មីៗ ពីការចរាចរឆ្លងកាត់ និងហូរចូលគ្រឿងញៀន ទាំងតាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស និងតាមបញ្ញើប្រៃសណីយ៍ ។ ជាក់ស្តែង ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៩ នេះ ករណីបទល្មើសគ្រឿងញៀនធំៗ នៅតាមច្រកព្រំដែនគោកនៃភាគឦសាន ភាគខាងលិច និងភាគខាងកើតប្រទេស នៅតាមអាកាសយានដ្ឋានអន្តរជាតិ នៅតាមបញ្ញើប្រៃសណីយ៍ ក៏ដូចជានៅតាមបណ្តាខេត្តគោលដៅទេសចរណ៍ ត្រូវបានស្រាវជ្រាវរកឃើញ និងបង្ក្រាបបាន រួមមាន ៖

- សមត្ថកិច្ចខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តរតនគីរី បង្ក្រាបបាន០៧ករណីផ្សេងគ្នា ឃាត់ខ្លួនជនសង្ស័យ០៨នាក់ ក្នុងនោះ ជនជាតិខ្មែរ០៤នាក់ ជនជាតិឡាវ០៣នាក់ និងជនជាតិឥណ្ឌូនេស៊ី០១នាក់ និងរឹបអូសបានគ្រឿងញៀនជាង ២០ គីឡូក្រាម
- សមត្ថកិច្ចខេត្តសៀមរាប សហការជាមួយកម្លាំងប្រចាំច្រកព្រលានយន្តហោះអន្តរជាតិសៀមរាប បង្ក្រាបបានករណីនាំគ្រឿងញៀនចេញទៅក្រៅប្រទេស០១ករណី ឃាត់ខ្លួនជនសង្ស័យបាន០៥នាក់ ជាជនជាតិបរទេស និងរឹបអូសគ្រឿងញៀនជាច្រើនប្រភេទសរុបជាង០៥គីឡូក្រាម និងបង្ក្រាបករណីជួញដូរ ប្រើប្រាស់គ្រឿងញៀននៅទីតាំងក្លឹបកម្សាន្ត០១ករណី ឃាត់ខ្លួនមនុស្ស៣០នាក់(ស្រី២៤នាក់)និងរឹបអូសសារធាតុញៀនមួយចំនួន
- សមត្ថកិច្ចខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ បង្ក្រាបបាន០៤ករណីផ្សេងគ្នា ឃាត់ខ្លួនជនសង្ស័យបាន០៨នាក់ ក្នុងនោះ ជនជាតិខ្មែរ០៤នាក់ និងជនជាតិថៃ០៤នាក់ និងរឹបអូសបានគ្រឿងញៀនជាង ១១គីឡូក្រាម ។ ទន្ទឹមនោះ សមត្ថកិច្ចក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក៏បានបង្ក្រាបករណីជួញដូរ និងប្រើប្រាស់គ្រឿងញៀននៅទីតាំងក្លឹបកម្សាន្ត០១ករណី ឃាត់ខ្លួនមនុស្ស១៥៥នាក់(ស្រី០៤នាក់) និងរឹបអូសសារធាតុញៀនមួយចំនួន
- សមត្ថកិច្ចខេត្តស្វាយរៀង បង្ក្រាបករណីនាំគ្រឿងញៀនឆ្លងដែនបាន០២ករណី រឹបអូសគ្រឿងញៀនជាង១៧គីឡូក្រាម ឃាត់ខ្លួនជនសង្ស័យ០២នាក់ ភេទស្រី ជនជាតិវៀតណាម ។ ជាមួយគ្នានេះ សមត្ថកិច្ចយោធាការពារព្រំដែនវៀតណាម បង្ក្រាបជាក់ស្តែងករណីជួញដូរគ្រឿងញៀនឆ្លងដែន(ពីកម្ពុជាទៅវៀតណាមតាមច្រករបៀង ក្នុងឃុំគ្រួស ស្រុកស្វាយជ្រុំ) ឃាត់ខ្លួនជនជាតិវៀតណាម០១នាក់ និងរឹបអូសគ្រឿងញៀនបានជាង៦០

គីឡូក្រាម ។ ក្នុងកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសទាំងពីរ សមត្ថកិច្ចខេត្តស្វាយរៀងសហការជាមួយកំលាំងមន្ទីរប្រឆាំងគ្រឿងញៀន ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បន្តឃាត់ខ្លួនជនសង្ស័យចំនួន០៧នាក់ រឹបអូសគ្រឿងញៀនបានជិតកន្លះគីឡូក្រាម ដែលពាក់ព័ន្ធនឹងករណីជួញដូរគ្រឿងញៀនឆ្លងដែនខាងលើ

- សមត្ថកិច្ចខេត្តព្រះសីហនុ និងខេត្តពោធិ៍សាត់ បង្ក្រាបបាន០២ករណីផ្សេងគ្នា ឃាត់ខ្លួនជនសង្ស័យបាន ០៦នាក់ ក្នុងនោះ ជនជាតិខ្មែរ០៣នាក់ ជនជាតិចិន០៣នាក់ និងរឹបអូសបានគ្រឿងញៀនជាង០៤គីឡូក្រាម ។ ទន្ទឹមនោះ ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ក៏បានបង្ក្រាបករណីជួញដូរ និងប្រើប្រាស់គ្រឿងញៀននៅទីតាំងក្លឹបកម្សាន្ត០១ករណី ឃាត់ខ្លួនមនុស្ស១៤៦នាក់(ស្រី៤៣នាក់) និងរឹបអូសសារធាតុញៀនមួយចំនួន
- ការបញ្ជូនគ្រឿងញៀនបង្កប់ក្នុងកញ្ចប់បញ្ញើប្រៃសណីយ៍ពីក្រៅប្រទេសចូលមកកម្ពុជា យើងបង្ក្រាបបាន ០៦ករណី ឃាត់ខ្លួនជនសង្ស័យ០៥នាក់ ក្នុងនោះ ជនជាតិខ្មែរ០៣នាក់(ស្រី០២នាក់)ជនជាតិចិន ០១នាក់ ភេទប្រុស និងជនជាតិនីហ្សេរីយ៉ា ០១នាក់ ភេទប្រុស រឹបអូសគ្រឿងញៀនអិចស្តាស៊ីជាង០៩គីឡូក្រាម និងកេតាមីនជាង០១គីឡូក្រាម ។

ជាមួយគ្នានេះដែរ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ សមត្ថកិច្ចមន្ទីរប្រឆាំងគ្រឿងញៀន និងស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានបង្ក្រាបបទល្មើសគ្រឿងញៀនទ្រង់ទ្រាយធំនៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន រួមមាន ៖

- ករណីជួញដូរប្រើប្រាស់គ្រឿងញៀនក្នុងមជ្ឈមណ្ឌលកម្សាន្តរ៉ក់០១ករណី ឃាត់ខ្លួនជនសង្ស័យ៣១១នាក់(ស្រី៥៦នាក់) និងរឹបអូសបានគ្រឿងញៀនជាច្រើនប្រភេទសរុបជាង៤៨គីឡូក្រាម
- ករណីផលិតកែច្នៃគ្រឿងញៀនប្រភេទថ្មី០១ករណី រឹបអូសបានវត្ថុតាងសារធាតុពីរ៉ូវ៉ាឡេរ៉ូនជាង១៧៣គីឡូក្រាម សារធាតុគីមីផ្សំជាង ៥០០គីឡូក្រាម និងឧបករណ៍សម្ភារផលិតមួយឈុត
- ករណីជួញដូរប្រើប្រាស់ និងផលិតកែច្នៃគ្រឿងញៀន០១ករណី នៅក្លឹបMIAMI ឃាត់ខ្លួនជនសង្ស័យ៥០នាក់(ស្រី១២នាក់) រឹបអូសគ្រឿងញៀនសរុបបានជាង៦១១,៤២ ក្រាម
- ករណីជួញដូរប្រើប្រាស់គ្រឿងញៀនក្នុងក្លឹបលុច្បសារី០១ករណី ឃាត់ខ្លួនជនសង្ស័យប្រមាណ៤០០នាក់ រឹបអូសបានគ្រឿងញៀន និងឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន
- ករណីជួញដូរគ្រឿងញៀនក្នុងទ្រង់ទ្រាយធំ១២ករណី ឃាត់ខ្លួនជនសង្ស័យ១៩នាក់(ស្រី៨នាក់) រឹបអូសគ្រឿងញៀនសរុបបានជាង២៣គីឡូក្រាម ។

ការអនុវត្តវិធានការអប់រំផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀន ក៏បានធ្វើសកម្មភាពយ៉ាងផុសផុល ដោយគ្របដណ្តប់ទៅលើអ្នកមកទទួលសារអប់រំ**ប្រមាណជិត ៦លាន នាក់** ។ ការអនុវត្តវិធានការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន យើងគ្រប់គ្រងបានអ្នកប្រើប្រាស់គ្រឿងញៀន**ប្រមាណជិត២ម៉ឺននាក់** ក្នុងនោះចំនួនអ្នកដែលមកទទួលយកសេវាព្យាបាលដោយស្ម័គ្រចិត្តមានការកើនឡើង ។ ការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់នៅតាមគោលដៅក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន ដោយធ្វើកិច្ចសន្យាជានាមិនឲ្យមានសកម្មភាពជួញដូរ ប្រើប្រាស់គ្រឿងញៀននៅក្នុងទីតាំងអាជីវកម្មរបស់ខ្លួន អនុវត្តបានជាច្រើនទីតាំងនៅទូទាំងប្រទេស ។ ទន្ទឹមនោះ បានធ្មក់ចូលត្រួតពិនិត្យរដ្ឋបាលផង និងឈានទៅអនុវត្តវិធានការផង ចំពោះទីតាំងក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន ដែលបណ្តែតបណ្តោយឲ្យមានសកម្មភាពបទល្មើសគ្រឿងញៀននៅក្នុងទីតាំងអាជីវកម្មរបស់ខ្លួន ព្រមទាំងបានឃាត់ខ្លួនមុខសញ្ញាពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនជាច្រើននាក់ ។

## II. អំពីការងារដឹកនាំ

ក្នុងគោលបំណងបង្ការ ទប់ស្កាត់ បង្ក្រាប និងដោះស្រាយឱ្យកាន់តែមានប្រសិទ្ធភាពនូវរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន ក៏ដូចជា ដើម្បីចូលរួមរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការអភិវឌ្ឍជូនប្រជា

ពលរដ្ឋ និងសង្គមជាតិ រាជរដ្ឋាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានយកចិត្តទុកដាក់ដឹកនាំ សម្របសម្រួល និងអនុវត្តប្រកបដោយការទទួលខុសត្រូវខ្ពស់នូវផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៤ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ក៏ដូចជាវិធានការចាំបាច់ និងការងារពាក់ព័ន្ធសំខាន់ៗផ្សេងទៀត រួមមានដូចជា៖

**១. ការងារដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនាមរាជរដ្ឋាភិបាល បានបន្តយកចិត្តទុកដាក់លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយបាន ៖

- ជួបសំណេះសំណាល និងបញ្រ្ជាបបញ្ហាគ្រឿងញៀន ដើម្បីជាការដាស់តឿនក្រើនរំលឹកដល់កម្មករ កម្មការិនី នៅតាមរោងចក្រ សហគ្រាសនានានៅទូទាំងប្រទេស បើគិតពីខែសីហា ឆ្នាំ២០១៧ មកដល់ខែមីនា ឆ្នាំ២០១៩ នេះ បានចំនួន៦៦លើក និងមានអ្នកចូលរួមជិត **១ លាន** នាក់ ។

- ប្រគល់ភារកិច្ចជូន **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ឯកឧត្តម **កែ គីមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ. ក្នុងនាមរាជរដ្ឋាភិបាលឲ្យបន្តការដឹកនាំអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៤ ដោយប្រមូលផ្តុំសមាសភាពពីគ្រប់មជ្ឈដ្ឋានសង្គម អនុវត្តនូវវិធានការសរុប ប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប ក្នុងការពង្រឹងយន្តការដែលមានស្រាប់ និងរៀបចំយន្តការចាំបាច់បន្ថែម ក៏ដូចជាកសាងផែនការសកម្មភាពមួយចំនួនទៀត ដើម្បីឲ្យការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៤ មានប្រសិទ្ធភាព មានការទទួលខុសត្រូវ និងកាន់តែទទួលបាននូវការចូលរួមគាំទ្រពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ។

- ប្រគល់ជូន**សម្តេចក្រឡាហោម ស ខេង**ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អញ្ជើញជាអធិបតីតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ ។

- ផ្ញើសារលិខិតអប់រំពីបញ្ហាគ្រឿងញៀន ជូនបងប្អូនជនរួមជាតិក្នុងឱកាសនៃការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ។

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ក្នុងឱកាសអញ្ជើញចុះសំណេះសំណាល សួរសុខទុក្ខ និងផ្តល់អំណោយមនុស្សធម៌កាកបាទក្រហម ដល់ប្រជាពលរដ្ឋដែលជួបប្រទះគ្រោះធម្មជាតិ និងនៅតាមវេទិកាមនុស្សធម៌នានា បានអំពាវនាវដល់គ្រប់សមត្ថកិច្ចអនុវត្តច្បាប់ ឲ្យខិតខំប្រើប្រាស់វិធានការជំនាញក្នុងការលុបបំបាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ពិសេសនៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន ដើម្បីចូលរួមអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ក៏ដូចជាបានអំពាវនាវដល់ប្រជាពលរដ្ឋទូទៅក្នុងសហគមន៍ ចូលរួមឲ្យបានសកម្មជាមួយអាជ្ញាធរដែនដី និងរាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ និងដោះស្រាយបញ្ហាគ្រឿងញៀននៅក្នុងមូលដ្ឋានរបស់ខ្លួន ។

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានផ្តល់អនុសាសន៍ដឹកនាំដោយកំណត់ឲ្យលុបបំបាត់ទាំងស្រុងនូវរាល់បទល្មើសជួញដូរ និងប្រើប្រាស់គ្រឿងញៀន ព្រមទាំងជំរុញបញ្ចប់ការធ្វើកិច្ចសន្យាមិនពាក់ព័ន្ធគ្រឿងញៀន នៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាននានាទូទាំងប្រទេស ឲ្យអស់

ក្នុងឆ្នាំ២០១៩នេះ ។ ជាមួយនេះ ក៏បានអំពាវនាវដល់គ្រប់មជ្ឈដ្ឋានសង្គម និងកំលាំងអនុវត្តច្បាប់ទាំងអស់ អនុវត្តនូវទិសស្លោក កុំ៣ ១រាយការណ៍ គឺ ៖ ១-កុំឲ្យពាក់ព័ន្ធ ២-កុំលើកលែង ៣-កុំអន្តរាគមន៍ និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន ។ ព្រមទាំងស្នើឲ្យពន្លឿនការអនុវត្តនីតិវិធីបង្កកទ្រព្យ ដើម្បីឲ្យការប្រមូលមូលនិធិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ឆ្លើយតបបានទៅនឹងតម្រូវការជាក់ស្តែងនៃបញ្ហាគ្រឿងញៀននៅកម្ពុជា ។

## ២. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន** ប្រធាន អ.ជ.ប.គ.ញ. បានណែនាំនូវគោលការណ៍សំខាន់ៗ ដែលបានដាក់ចេញក្នុងសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ និងកិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ កាលពីថ្ងៃទី២០-២១ ខែមីនា ឆ្នាំ២០១៩ ក៏ដូចជានៅក្នុងកិច្ចប្រជុំរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ កន្លងទៅ ដែលក្នុងនោះរួមមាន៖ ការងារអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន , ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន , ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ , ការត្រួតពិនិត្យសារធាតុគីមីផ្សំ , កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា និងការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការអនុវត្តផែនការជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន(២០១៩-២០២៣) ការបន្តអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ ក៏ដូចជាការអនុវត្តនូវទិសដៅការងារត្រួតពិនិត្យគ្រឿងញៀនក្នុងឆ្នាំ២០១៩ នេះ ។

ក្រៅពីបានណែនាំខាងលើ នៅក្នុងរយៈពេល៩ខែ ឆ្នាំ២០១៩ នេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ប្រធាន អ.ជ.ប.គ.ញ. ក៏បាន ៖

- ដឹកនាំសិក្ខាសាលា ស្តីពីការងារត្រួតពិនិត្យគ្រឿងញៀននៅទិសពាយព្យ និងការអនុវត្តន៍សាកល្បងភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន នៅតាមព្រំដែន កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ នៅខេត្តស្ទឹងត្រែង
- ដឹកនាំសិក្ខាសាលា ស្តីពីការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ នៅទីស្តីការក្រសួងសុខាភិបាល
- ដឹកនាំកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងមហាផ្ទៃ
- ដឹកនាំអង្គសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ និងកិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ កាលពីថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងមហាផ្ទៃ
- អញ្ជើញចូលរួមជាអធិបតីក្នុងពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ មិថុនា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- ដឹកនាំកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងមហាផ្ទៃ

- អញ្ជើញជាអធិបតីក្នុងពិធីបើកកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីគ្រឿងញៀន(ASOD) លើកទី៤០ ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ នៅខេត្តសៀមរាប

- ជួបសំណេះសំណាលជាមួយមន្ត្រីរាជការ សិស្សានុសិស្ស និងប្រជាពលរដ្ឋ និងបានធ្វើការបញ្ជ្រាបខ្លឹមសារអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀន ។

ក្រៅពីការងារពាក់ព័ន្ធនឹងកិច្ចការត្រួតពិនិត្យគ្រឿងញៀន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ប្រធាន អ.ជ.ប.គ.ញ. ក៏បាន ៖

- អញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ និងរដ្ឋបាលខេត្តប៉ៃលិន

- អញ្ជើញជាអធិបតីតំណាងដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**ក្នុងពិធីប្រារព្ធខួបលើកទី៧០ ទិវាកុមារអន្តរជាតិ១មិថុនា និងខួបលើកទី១៨ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ

- អញ្ជើញជាអធិបតីតំណាងដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងខួបលើកទី១២ ទិវាអតីតយុទ្ធជនកម្ពុជា ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ នៅនៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ

- អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសសមាសភាពក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋានខេត្តបន្ទាយមានជ័យ ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ នៅខេត្តបន្ទាយមានជ័យ ។

ឯកឧត្តម នាយឧត្តមសេនីយ៍ ជួន សុវណ្ណ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រៅពីបានទទួលជួយលើការងារដឹកនាំរួមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញជាអធិបតីក្នុងអង្គសិក្ខាសាលាអង្គសន្និបាត ទិវាអន្តរជាតិពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏បាន ៖ អញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨និងលើកទិសដៅការងារឆ្នាំ២០១៩របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ អញ្ជើញជាអធិបតីក្នុងពិធីបើកបវេសនកាល ឆ្នាំសិក្សា២០១៩-២០២០ នៅវិទ្យាល័យឥន្ទ្រទេវីរាជធានីភ្នំពេញ, អញ្ជើញជាអធិបតីក្នុងពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ នៅខេត្តបន្ទាយមានជ័យ , អញ្ជើញចុះត្រួតពិនិត្យការងារសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ និងដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារប្រចាំខែរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ។ ជាមួយគ្នានេះ ឯកឧត្តម នាយឧត្តមសេនីយ៍ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏បានដឹកនាំគណៈប្រតិភូកម្ពុជា ទៅចូលរួមក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ស្តីពីការពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មគ្រឿងញៀនឆ្លងដែន និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ត្រីភាគី/ទ្វេភាគី កម្ពុជា ឡាវ វៀតណាម លើកទី១៨ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ពីថ្ងៃទី០៩ ដល់១៤ ខែកញ្ញា ឆ្នាំ២០១៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៩ នេះ យោងតាមផែនការជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក៏ដូចជាការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៤ និងទិសដៅការងារដែលបានដាក់ចេញក្នុងឆ្នាំ២០១៩ នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមទាំងក្រសួង-ស្ថាប័ន សមាជិក និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានខិតខំបន្តអនុវត្តការងារដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

អនុវត្តតាមគោលការណ៍ដឹកនាំ ឲ្យបង្កើនការអប់រំផ្សព្វផ្សាយទៅលើគោលដៅប្រឈមខ្ពស់ឲ្យបានសកម្ម និងផុលផុសថែមទៀត ដូចជា ផ្ទះសំណាក់ សណ្ឋាគារ កន្លែងកម្សាន្តសប្បាយ ការដ្ឋានសំណង់ ក្រុមហ៊ុនដឹកជញ្ជូន លំនៅដ្ឋានកម្មករក្រៅប្រព័ន្ធ។ល។ដោយចលនាឲ្យមានការចូលរួមពីគ្រប់សមាសភាពសង្គម បញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនប្រកបដោយគុណភាព ពិសេសបោះពុម្ពទិសស្លោករបស់**សម្តេចក្រឡាហោម ស ខេង** កុំ៣ ១រាយការណ៍ គឺ ៖ ១-កុំឲ្យពាក់ព័ន្ធ ២-កុំលើកលែង ៣-កុំអន្តរាគមន៍ និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន ដើម្បីផ្សព្វផ្សាយទៅគ្រប់វេទិកា និងព្រឹត្តការណ៍ផ្សេងៗ ក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត រៀបចំឲ្យមានខ្លឹមសារហាមឃាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀននៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់សណ្ឋាគារ ផ្ទះសំណាក់។ល។ បន្តជំរុញឲ្យដាក់សារអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀននៅគ្រប់ផលិតផល បន្តបើកវគ្គបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋានអំពីគ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មេឃុំ ចៅសង្កាត់ នាយនគរបាលប៉ុស្តិ៍រដ្ឋបាល និងមន្ត្រីទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់ឃុំ សង្កាត់ ក៏ដូចជាត្រូវសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំទីកន្លែងអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀនស្របតាមគោលនយោបាយជាតិ ស្តីពីសុខភាពសិក្សា សម្រាប់ថ្នាក់ជាតិ ឲ្យបាន០១កន្លែងនៅរាជធានីភ្នំពេញ និងនៅតាមអនុវិទ្យាល័យទូទាំងប្រទេស ។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមជាមួយក្រសួង ស្ថាប័ន សមាជិក និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានអនុវត្តការងារដោយទទួលនូវលទ្ធផលដូចខាងក្រោម ៖

#### ១.១ ការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ៖

ក្រសួង-ស្ថាប័ន សមាជិក អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានចូលរួមផ្តល់បទសម្ភាសន៍ពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន តាមប្រព័ន្ធផ្សព្វផ្សាយដូចជាវិទ្យុ-ទូរទស្សន៍ រដ្ឋ និងឯកជន ។ បានបញ្ចូលខ្លឹមសារអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀននៅក្នុងផលិតផលភាពយន្ត បណ្តាញទូរស័ព្ទចល័ត បណ្តាញសារព័ត៌មានអេឡិកត្រូនិច និងផ្សព្វផ្សាយជាឃ្លីបវីដេអូខ្លី ស្តីពីគ្រឿងញៀននៅតាមគេហទំព័រ ក៏ដូចជាក្នុងPage Facebook ជាដើម។ល។ ក្នុងនោះផងដែរ ៖

- តាមរយៈគេហទំព័រ អ.ជ.ប.គ.ញ. (www.nacd.gov.kh)មានអ្នកចូលអានសរុប**២០៥.៨៤៧ ដង** ។
- តាមរយៈទូរស័ព្ទចល័តនៃក្រុមហ៊ុនទូរស័ព្ទចល័តទាំង០៥ បានបញ្ជូនសារអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន មានចំនួនសរុប **៣៤.១២៣.៥១៩ លេខ ស្មើនឹង ១៩០,៤៥ % នៃចំនួនស៊ីមកាតកំពុងប្រើប្រាស់សរុប** ។
- តាមរយៈសិល្បភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ បានបញ្ចូលសារអប់រំអំពីគ្រឿងញៀន " គ្រឿងញៀនបង្កឲ្យមានអំពើហឹង្សា និងឧក្រិដ្ឋកម្ម"ទៅក្នុងផលិតផលភាពយន្តទាំងខ្មែរ និងបរទេសរបស់បណ្តាក្រុមហ៊ុនផលិតកម្មនានា បានចំនួន**១.៧៥២.០៣៦ ឌីស** ។

**១.២ កម្មវិធីអប់រំផ្សព្វផ្សាយតាមសហគមន៍ ៖**

ការងារអប់រំផ្សព្វផ្សាយតាមសហគមន៍ មានដូចជា កម្មវិធីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម វេទិកាសាធារណៈ ពិធីសំណេះសំណាល ព្រឹត្តិការណ៍សង្គមផ្សេងៗ។ល។ នៅតាមវត្តអារាម គ្រឹះស្ថានអប់រំ រោងចក្រ សហគ្រាស និងការចែកចាយខិត្តប័ណ្ណពាក់ព័ន្ធនឹងការងារបង្ការ ទប់ស្កាត់ការចរាចរ ជួញដូរ រក្សាទុក ប្រើប្រាស់គ្រឿងញៀន និងផ្សព្វផ្សាយអំពីការព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមប្រព័ន្ធសុខាភិបាលមូលដ្ឋាន ក្នុងនោះ ៖

**១.២.១.** បុគ្គលិក កម្មករ កម្មការិនីប្រមាណ **៧ម៉ឺន** នាក់ បានទទួលសារអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀនពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងពិធីជួបសំណេះសំណាលនៅតាមបណ្តារោងចក្រ ។

**១.២.២.** ប្រជាពលរដ្ឋ យុវជន យុវនារី កុមារកំព្រា ពិការក្នុងមជ្ឈមណ្ឌលមួយចំនួន និងជនរងគ្រោះដោយសារឧបទ្ទវហេតុផ្សេងៗ ប្រមាណ**៣ម៉ឺន**នាក់ បានទទួលសារអប់រំអំពីបញ្ហាគ្រឿងញៀនពី **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ក្នុងឱកាសសម្តេចចុះសំណេះសំណាល សួរសុខទុក្ខ ផ្តល់អំណោយមនុស្សធម៌កាកបាទក្រហម នៅតាមវេទិកាមនុស្សធម៌នានា ក្នុងរាជធានី-ខេត្ត ។

**១.២.៣.** មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សិស្សានុសិស្ស ប្រជាពលរដ្ឋ ប្រមាណ **៥ម៉ឺន**នាក់ បានទទួលសារអប់រំអំពីបញ្ហាគ្រឿងញៀនពី **សម្តេចក្រឡាហោម ស ខេង** ក្នុងឱកាសសម្តេចចុះជួបសំណេះសំណាលនៅតាមរាជធានី-ខេត្ត ។

**១.២.៤.** មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សិស្សានុសិស្ស ប្រជាពលរដ្ឋ ប្រមាណ**៥ម៉ឺន**នាក់ បានទទួលសារអប់រំអំពីបញ្ហាគ្រឿងញៀនពី **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន** ក្នុងពិធីជួបសំណេះសំណាលនៅតាមវេទិកានានា ។

**១.២.៥.** អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំ និងណែនាំឲ្យរាជធានី-ខេត្ត ចាត់តាំងប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ដែលមានអ្នកចូលរួមប្រមាណ**៥ម៉ឺន** នាក់ ។

**១.២.៦.** ក្រសួងសមាជិក អ.ជ.ប.គ.ញ. រួមមាន ៖ ក្រសួងអប់រំ យុវជន និងកីឡា , ក្រសួងកិច្ចការនារី , ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ , ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច , ក្រសួងសាធារណការ និងដឹកជញ្ជូន , ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ , ក្រសួងធម្មការ និងសាសនា , ក្រសួងការពារជាតិ , ធនាគារជាតិនៃកម្ពុជា , ក្រសួងយុត្តិធម៌ , ក្រសួងទេសចរណ៍ , ក្រសួងសុខាភិបាល , ក្រសួងបរិស្ថាន, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម , ក្រសួងផែនការ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានធ្វើការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀននៅក្នុងវិស័យជំនាញរបស់ខ្លួន ដោយគ្របដណ្តប់លើអ្នកមកទទួលសារអប់រំចំនួន **១.០៩៧.៨៦៧** នាក់ ។

**១.២.៧.** គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនទាំង២៥ រាជធានី-ខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន បានចំនួន**៦៧.៤១៧**លើក ដោយគ្របដណ្តប់លើអ្នកមកទទួលយកសារអប់រំ**២.៩២១.២៤៧**នាក់/ស្រី **១.៤៦៦.៣៦៣** នាក់ ក្នុងនោះ ៖ តាមគ្រឹះស្ថានសិក្សា **៣.២១៥**លើក អ្នកចូលរួម **៤៨៦.២៣២** នាក់/ស្រី **២៣៦.៨៤១**នាក់ , តាមវេទិកាសាធារណៈ **៤៨.០៧៤** លើក អ្នកចូលរួម **២.២០៥.៦៣០**នាក់/ស្រី**១.០៧៧.៤១១**នាក់,តាមរយៈវិស័យសាសនា **១.៨៩១**លើក អ្នកចូលរួម**២៤០.៩៦៨**នាក់/ស្រី**១៤៥.៨០៩**នាក់ , តាមរយៈប្រព័ន្ធផ្សព្វផ្សាយ **១២.៣១១**លើក និងចុះចែកខិត្តប័ណ្ណ **១.៥៦៧** លើក ស្មើនឹង **៩៤.៤៤៦** សន្លឹក និងនៅតាមរោងចក្រ សហគ្រាស ពន្ធនាគារ អង្គភាព **៣៥៩** លើក អ្នកចូលរួម **១៨.៤១៧** នាក់/ស្រី **៦.២០២** នាក់ ។

**១.២.៨.** ការបញ្ជ្រាបខ្លឹមសារអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមកម្មវិធីប្រគុំតន្ត្រីរបស់ក្រុមហ៊ុនភេសជ្ជៈមួយចំនួន ដោយគ្របដណ្តប់លើអ្នកមកទទួលយកសារអប់រំប្រមាណ **៨០ម៉ឺន** នាក់ ។

**១.២.៩.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. រួមជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានជម្រុញសកម្មភាពអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន នៅក្នុងឱកាសពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ ដោយគ្របដណ្តប់លើអ្នកដែលបានទទួលសារអប់រំ**១លាន ២សែន** នាក់។

➢ សរុបអ្នកដែលបានមកទទួលសារអប់រំពីបញ្ហាគ្រឿងញៀន មានចំនួន **៥.៩៤៧.៣០៤** អង្គ/នាក់ បើធៀបនព្វមាស ឆ្នាំ២០១៨(**៥.៧៧៩.០៤២ នាក់**) មានការកើនឡើងចំនួន **១៦៨.២៦២** អង្គ/នាក់ ។

ជាមួយគ្នានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបែងចែកឯកសារ និងសម្ភារអប់រំផ្សព្វផ្សាយពីបញ្ហានៃគ្រឿងញៀនគ្រប់ប្រភេទ ទាំងសម្រាប់បម្រើការចាត់តាំងប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ក៏ដូចជានៅក្នុងកម្មវិធីអប់រំផ្សព្វផ្សាយនានា ដល់ក្រសួង-ស្ថាប័ន គណៈ-កម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ រួមមាន៖

- សៀវភៅច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ២.៨៦០ ក្បាល
- សៀវភៅចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន ១.០៨០ ក្បាល
- ខិត្តប័ណ្ណផ្សព្វផ្សាយ ២៩.០០០ សន្លឹក
- អាវយឺត និងមួក ៣០.០០០ កំប្លេ
- បដាចង ១៥០
- បដាកាន់ដៃ ២៥០
- ផ្ទាំងរូបភាព ៥.០០០ សន្លឹក

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យបន្តពង្រឹងគុណភាពសេវាព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ(មណ្ឌលសុខភាព-មន្ទីរពេទ្យបង្អែក) ការពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ និងឯកជនឲ្យបន្តដំណើរការសាងសង់ ការរៀបចំឲ្យមានគណៈគ្រប់គ្រង ការរៀបចំឲ្យមានកម្មវិធី និងបទដ្ឋានពាក់ព័ន្ធនានាសម្រាប់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ ដើម្បីអាចទទួលយកជនរងគ្រោះដោយសារគ្រឿងញៀននាចុងឆ្នាំ២០១៩ ក៏ដូចជាការឲ្យរៀបចំតម្លើងបញ្ជីឈ្មោះឃុំ-សង្កាត់ទូទាំងប្រទេស ឲ្យបាន២៥%លើចំនួនឃុំ-សង្កាត់គោលដៅជាង៤០០ ដែលបានបើកបម្រើសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួង-ស្ថាប័នជាសមាជិក រួមនិងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានខិតខំបន្តអនុវត្តការងារដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់ ៖

ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៩ នេះ ការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួងសុខាភិបាលជាសេនាធិការ និងការគាំទ្រចំពោះអង្គការដៃគូ បាន ៖

– បន្តផ្តល់សេវាព្យាបាលដោយឱសថជំនួសមេតាដូន ដល់អ្នកញៀនគ្រឿងញៀនពួកអាភៀន នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមន្ទីរពេទ្យបង្អែកមានជ័យ រាជធានីភ្នំពេញ ដែលមានអ្នកទៅទទួលសេវាចំនួន ៩៨ នាក់ ស្រី ១១ នាក់

– បន្តអនុវត្តនូវកម្មវិធីម្ជុល/ស៊ីរ៉ាំងចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ដែលគ្របដណ្តប់ទៅលើអ្នកចាក់គ្រឿងញៀនចំនួន ៦២៧ នាក់ ស្រី ១២៧នាក់។

ជាមួយគ្នានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសម្របសម្រួល និងចាត់បញ្ជូនមន្ត្រីពាក់ព័ន្ធឲ្យទៅចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា និងធ្វើបទបង្ហាញ រួមមាន ៖

– កិច្ចប្រជុំ ស្តីពីការឆ្លើយតបរួមគ្នាក្នុងអន្តរាគមន៍នៃមេរោគអេដស៍/ជំងឺអេដស៍ និងគ្រឿងញៀន

– សិក្ខាសាលា ស្តីពីការកំណត់ទស្សនវិស័យនៃផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥

– កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការលើកកម្ពស់ភាពជាដៃគូរវាងអ្នកអនុវត្តច្បាប់ ជាមួយសង្គមស៊ីវិលចំពោះកម្មវិធីអេដស៍ និងសេវាគាំទ្រផ្សេងៗ ដល់អ្នកប្រើប្រាស់គ្រឿងញៀន

– ធ្វើបទបង្ហាញស្តីពីគ្រឿងញៀននៅក្នុងសិក្ខាសាលា ការលើកកម្ពស់ការយល់ដឹងពីមេរោគអេដស៍ ជំងឺអេដស៍ និងឥទ្ធិពលនៃគ្រឿងញៀន

– កិច្ចប្រជុំរបស់គណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន នៅកន្លែងធ្វើការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

– សិក្ខាសាលាពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការអន្តរនាយកដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន នៃក្រសួងអប់រំ យុវជន និងកីឡា

– ធ្វើបទបង្ហាញស្តីពីគ្រឿងញៀននៅក្នុងកម្មវិធីអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងវិស័យបរិស្ថាន

– ធ្វើបទបង្ហាញស្តីពីគ្រឿងញៀននៅក្នុងសិក្ខាសាលា ស្តីពីការលើកកម្ពស់ការយល់ដឹងពីមេរោគអេដស៍ ជំងឺអេដស៍ និងឥទ្ធិពលនៃគ្រឿងញៀន ។

## ២.២. ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ៖

ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៩ នេះ យើងបានគ្រប់គ្រងអ្នកប្រើប្រាស់គ្រឿងញៀន មានចំនួន **១៩.២៧២** នាក់ ក្នុងនោះ ៖

តាមរបាយការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៖

- អ្នកដែលបានជាសះស្បើយពីគ្រឿងញៀន ធ្វើសមាហរណកម្មចេញពីមណ្ឌល មាន **៧.១៨២** នាក់
- អ្នកញៀនគ្រឿងញៀន ដែលបន្តធ្វើការបន្សាបព្យាបាលនៅតាមមណ្ឌល មាន **៤.០០០** នាក់

តាមរបាយការណ៍របស់ក្រសួងសុខាភិបាល ៖

- អ្នកញៀនគ្រឿងញៀន ដែលបានមកទទួលសេវាពិនិត្យ ព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលក្នុងរាជធានី-ខេត្ត មាន **៨.៦០៧** នាក់

តាមរបាយការណ៍របស់លេខាធិការដ្ឋានយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៩នេះ ក្នុងចំណោមជនសង្ស័យប្រើប្រាស់គ្រឿងញៀនដែលបានឃាត់ខ្លួន(៧.១៤៩ នាក់) និងក្រៅពីបានចាត់វិធានការបញ្ជូនទៅមណ្ឌល(៤.៦២៦នាក់) គឺសមត្ថកិច្ចបានធ្វើការអប់រំបញ្ជូនទៅមូលដ្ឋានវិញចំនួន ១.៩៤៧នាក់ និងបានចាត់វិធានការបញ្ជូនទៅពន្ធនាគារចំនួន ៥៧៦នាក់ សរុបតួលេខដែលត្រូវបានគិតបញ្ចូលទៅក្នុងចំនួនអ្នកប្រើប្រាស់គ្រឿងញៀនដែលយើងគ្រប់គ្រងបានខាងលើ(១.៩៤៧ នាក់ + ៥៧៦ នាក់) **គឺមានចំនួន ២.៥២៣ នាក់** ។

**ជាមួយគ្នានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ៖**

– ជំរុញឲ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ពង្រឹង និងបង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅតាមឃុំ-សង្កាត់ ដើម្បីគាំទ្រឲ្យអ្នកប្រើប្រាស់និងអ្នកញៀនគ្រឿងញៀនមានភាពងាយស្រួលទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្តនៅតាមសហគមន៍

– បន្តការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដែលក្នុងនោះបានសម្រេចការសាងសង់អគាររដ្ឋបាលចំនួន១ អគារអគ្គីសនីចំនួន១ អគារចំរោះទឹកស្អាតចំនួន១ អគារព្យាបាលចំនួន១ អគារស្នាក់នៅបុរសចំនួន១ អគារស្នាក់នៅស្ត្រីចំនួន១ អគារបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន១ និងរបងព័ទ្ធជុំវិញមណ្ឌល ។ ជាមួយនេះ បាននឹងកំពុងសាងសង់ហេដ្ឋរចនាសម្ព័ន្ធផ្លូវ និងលូ

– បាន និងកំពុងជំរុញការងាររៀបចំទិន្នន័យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន ឲ្យស៊ីសង្វាក់គ្នារវាងស្ថាប័នអនុវត្តច្បាប់ ជាមួយនឹងស្ថាប័នផ្តល់សេវាសុខភាព និងសង្គមកិច្ច

– បាន និងកំពុងជំរុញ និងសម្របសម្រួលក្នុងការរៀបចំមន្ត្រី បុគ្គលិកសម្រាប់គ្រប់គ្រង និងបម្រើការងារនៅមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ

– បាន និងកំពុងសម្របសម្រួលជាមួយភាគីវៀតណាម ដើម្បីរៀបចំកិច្ចព្រមព្រៀងថ្នាក់រដ្ឋាភិបាលក្នុងការអនុវត្តគម្រោងសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀន នៅខេត្តព្រះសីហនុ

– បានរៀបចំគម្រោងស្នើសុំជំនួយពីរដ្ឋាភិបាលចិន ពាក់ព័ន្ធនឹងការគាំទ្រមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅខេត្តព្រះសីហនុ

– បាន និងកំពុងសហការពិភាក្សាជាមួយក្រសួងមហាផ្ទៃ អំពីគម្រោងសាងសង់មជ្ឈមណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀននៅខេត្តពោធិ៍សាត់ ។

**ដោយឡែកក្រសួងសុខាភិបាល** ក្នុងរយៈពេល៩ខែនេះ បានដំណើរការសេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន បាន **៤៥០** កន្លែង នៅទូទាំងប្រទេស ក្នុងនោះ ៖ មន្ទីរពេទ្យថ្នាក់ជាតិ២កន្លែង , មន្ទីរពេទ្យខេត្ត២៤កន្លែង , មន្ទីរពេទ្យបង្អែក៧៣កន្លែង និងមណ្ឌលសុខភាព ៣៥១កន្លែង បានដំឡើងស្លាកសញ្ញាសម្គាល់ទីតាំងផ្តល់សេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន បាន ៣៤៥ទីតាំង ស្មើនឹង ៨២% លើចំនួនទីតាំងផ្តល់សេវាសរុប ។

➢ **កត់សម្គាល់** សរុបសេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន ចំនួន **៤៥០** កន្លែង បើគិតទៅនឹងឆមាសទី១/ឆ្នាំ២០១៩(**៤៣១**កន្លែង) មានការកើនឡើងថ្មី**១៩**កន្លែង គឺ ៖ ខេត្តព្រះវិហារចំនួន**១០**កន្លែង(មណ្ឌលសុខភាព) និងខេត្តស្ទឹងត្រែងចំនួន**០៩**កន្លែង(មណ្ឌលសុខភាព) ។

## ២.៣. ការពង្រឹងសមត្ថភាពព្យាបាល និងស្តារនីតិសម្បទា ៖

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួងសុខាភិបាលជាសេនាធិការ បានរៀបចំ ៖

– វគ្គបណ្តុះបណ្តាល ស្តីពីភាពញៀនគ្រឿងញៀនដល់មន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមូលដ្ឋាន នៅរាជធានីភ្នំពេញ

- កិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការអនុវត្តគម្រោងសាកល្បង ការងារព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ នៅរាជធានីភ្នំពេញ
- កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការឆ្លើយតបរួមគ្នាអំពីជំងឺអេដស៍ និងគ្រឿងញៀន
- កិច្ចប្រជុំសម្របសម្រួលបច្ចេកទេស ដើម្បីត្រួតពិនិត្យការងារ ភាពជាដៃគូរវាងវិស័យសុខាភិបាល រដ្ឋអំណាចមូលដ្ឋាន និងមន្ត្រីអនុវត្តច្បាប់ ក្នុងការអនុវត្តការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- សិក្ខាសាលា ស្តីពីការកសាងផែនការប្រតិបត្តិ និងប្រព័ន្ធព័ត៌មានសុខភាពផ្លូវចិត្ត និងគ្រឿងញៀន
- វគ្គបណ្តុះបណ្តាល ស្តីពីសុខភាពផ្លូវចិត្ត និងគ្រឿងញៀនសម្រាប់គ្រូពេទ្យព្យាបាល
- សិក្ខាសាលា ស្តីពីលក្ខណៈទូទៅនៃវិធីបង្ការ និងព្យាបាលជំងឺដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ។

ជាមួយគ្នានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចាត់បញ្ជូនមន្ត្រីពាក់ព័ន្ធទៅចូលរួម ៖

- វគ្គបណ្តុះបណ្តាល ស្តីពីការព្យាបាលជាសាកលសម្រាប់អ្នកប្រើសារធាតុញៀន(UTC)កម្រិតខ្ពស់ នៅប្រទេសថៃ
- វគ្គបណ្តុះបណ្តាល ស្តីពីការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅប្រទេសឥណ្ឌា
- វគ្គបណ្តុះបណ្តាល ស្តីពីការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅប្រទេសប្រទេសថៃ
- សិក្ខាសាលា ស្តីពីការបង្ការ និងព្យាបាលអ្នកប្រើបំពានគ្រឿងញៀន នៅខេត្តសៀមរាប ។
- សន្និសីទអាស៊ានលើកទី៧ សម្រាប់ឆ្នាំ២០១៩ ស្តីពីការថែទាំសុខភាពដែលមានលក្ខណៈទូលំទូលាយក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀន នៅប្រទេសថៃ
- កិច្ចសន្ទនា ស្តីពីយុទ្ធនាការបញ្ឈប់ការរើសអើងជនរងគ្រោះដោយសារគ្រឿងញៀន និងផ្តល់ការគាំទ្រឲ្យទៅរកសេវាសុខភាព ។

**ដោយឡែក ពាក់ព័ន្ធនឹងសកម្មភាពការងារពង្រឹងសមត្ថភាពព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនមួយចំនួនទៀត មានចែងលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធ ។**

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យបន្តពង្រឹងប្រសិទ្ធភាពអនុវត្តច្បាប់ ដើម្បីបំផ្លាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀន ដោយសហការយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង និងទប់ស្កាត់ការហូរចូលឲ្យបានជាអតិបរមានូវគ្រឿងញៀនគ្រប់ប្រភេទ ពិសេសនៅតំបន់ព្រំដែនកម្ពុជា-ឡាវ ។ បន្តពង្រឹងកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ជំរុញបញ្ចប់ការធ្វើកិច្ចសន្យាសហការលុបបំបាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀននៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋានដែលពាក់ព័ន្ធនឹងគ្រឿងញៀន ។ បន្តពង្រឹង និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន(BLO)ក៏ដូចការលើកកម្ពស់ជំនាញមន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន ។ បន្តស្រាវជ្រាវ និងបង្ក្រាបករណីផលិតកែច្នៃគ្រឿងញៀន និងករណីដាំដុះដំណាំកញ្ឆា។ បន្តពង្រឹងសមត្ថភាព ឆន្ទៈ គុណធម៌ស្មោះត្រង់នឹងវិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់ តាមទិសស្លោកកុំ៣ ១រាយការណ៍របស់ **សម្តេចក្រឡាហោម ស ខេង** គឺ ៖ ១-កុំឲ្យពាក់ព័ន្ធ ២-កុំលើកលែង ៣-កុំអន្តរាគមន៍ និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន ។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តសម្របសម្រួលជាមួយស្ថាប័នអនុវត្តច្បាប់ និងអនុវត្តការងារទទួលបាននូវលទ្ធផលដូចខាងក្រោម ៖

## ៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តសម្របសម្រួលរៀបចំ និងចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលសំខាន់ៗ ទាំងនៅក្នុង និងក្រៅប្រទេស រួមមាន ៖

– សិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន(BLO) ក្នុងការទំនាក់ទំនង និងសម្របសម្រួលការងារត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនកម្ពុជា-ឡាវ កម្ពុជា-ថៃ និងកម្ពុជា-វៀតណាម

– វគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង

– ទៅធ្វើបទឧទ្ទេសនាមអំពីចំណេះដឹងជាមូលដ្ឋាននៃគ្រឿងញៀនដល់សិស្សថ្នាក់មូលដ្ឋានជំនាន់ទី១០ នៅវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល នៃកងយោធពលខេមរភូមិន្ទ

– សិក្ខាសាលា ស្តីពីការបង្កើនសមត្ថភាពមន្ត្រីអនុវត្តច្បាប់ក្នុងកិច្ចការពារលើស្ត្រី និងកុមារីនៅតាមខ្សែបន្ទាត់ព្រំដែន

– កិច្ចប្រជុំពិភាក្សាក្នុងការលើកកម្ពស់តួនាទីស្ត្រីនៅក្នុងវិស័យអនុវត្តច្បាប់ និងកិច្ចការពារសហគមន៍

– វគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅប្រទេសចិន

– វគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់បទល្មើសគ្រឿងញៀននៅតាមព្រលានយន្តហោះ

– វគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មេឃុំ ចៅសង្កាត់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងមន្ត្រីទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅតាមឃុំ សង្កាត់

– វគ្គបណ្តុះបណ្តាល ស្តីពីទំនាក់ទំនង និងសម្របសម្រួលក្នុងការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនកម្ពុជា វៀតណាម ។

ជាមួយគ្នានេះ ៖

– លេខាធិការដ្ឋាននៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ បានរៀបចំកិច្ចប្រជុំដើម្បីពង្រឹងកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន នៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន ដែលមានការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ក្នុងក្របខណ្ឌទូទាំងប្រទេស ។

– អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងក្រសួងនគរបាលវៀតណាម បានជួបប្រជុំពិភាក្សាគ្នាអំពីការអនុវត្តផែនការចំណុចខ្ពស់នៃយុទ្ធនាការ ការឃោសនា និងបង្ក្រាបបទល្មើសគ្រឿងញៀននៅតាមបណ្តោយព្រំដែនកម្ពុជា វៀតណាម

– ក្រសួងមហាផ្ទៃ បានដាក់ចេញនូវផែនការ ស្តីពីយុទ្ធនាការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀននៅតាមបណ្តោយព្រំដែនកម្ពុជា វៀតណាម ។

– អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានទទួលវេនធ្វើជាម្ចាស់ផ្ទះរៀបចំមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ(Safe Mekong Coordination Centre) ដែលមានមន្ត្រីសម្របសម្រួលប្រចាំការមកពីបណ្តាប្រទេសសមាជិកSMCCទាំង៦ គឺ កម្ពុជា ថៃ ឡាវ ចិន វៀតណាម និងមីយ៉ាន់ម៉ា ក្នុងរយៈពេល៣ខែ ដោយគិតចាប់ពីខែកញ្ញា ឆ្នាំ២០១៩ នេះទៅ ។

**ដោយឡែក ពាក់ព័ន្ធនឹងសកម្មភាពការងារពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់មួយចំនួនទៀត មានចែងលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធ ។**

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន [2] ៖

– បទល្មើសគ្រឿងញៀនសរុប បង្ក្រាបបាន **៧.២៨៨** ករណី (ធៀបនឹងឧសភា/២០១៨ **៥.៦៤១** ករណី) កើនលើស **១.៦៤៧** ករណី ស្មើនឹង **២៩** % ក្នុងនោះ ៖

- ករណីជួញដូរ រក្សាទុក **៤.៣៤០** ករណី
- ករណីប្រើប្រាស់ **២.៩២៥** ករណី
- ដាំដុះ **២២** ករណី
- កែច្នៃផលិត **០១** ករណី

– **ជនសង្ស័យសរុប** ឃាត់ខ្លួនមាន **១៥.៤៧៨** នាក់ /ស្រី **១.០៤៨**នាក់(ធៀបនឹងឧសភា/២០១៨ **១១.៨៤៧** នាក់) កើនលើស **៣.៦៣១** នាក់ ស្មើនឹង **៣១** % ក្នុងនោះ ៖

- ជនសង្ស័យក្នុងករណីជួញដូរ រក្សាទុក **៨.៣២៤** នាក់ (ស្រី ៦៩៣ នាក់)
- ជនសង្ស័យក្នុងករណីប្រើប្រាស់គ្រឿងញៀន **៧.១៤៩** នាក់ (ស្រី ៣៥៥ នាក់)
- ជនសង្ស័យក្នុងករណីដាំដុះ **០៥** នាក់ ភេទប្រុស

ជនសង្ស័យរួមមាន ៖ ជនជាតិ**ខ្មែរ ១៥.១៣៤ នាក់(ស្រី ៩៨៨នាក់) និងជនបរទេស ៣៤៤ នាក់ (ស្រី៦០នាក់)** ស្មើនឹង ១៤ជនជាតិ គឺ ៖ វៀតណាម ១២៤នាក់(ស្រី៣៨នាក់) , ចិន ១៧៩នាក់(ស្រី២០នាក់) , កូរ៉េ ០២នាក់ , តៃវ៉ាន់ ០២នាក់ , ឡាវ ០៨នាក់ , ថៃ ១១នាក់(ស្រី០២នាក់) , នីហ្សេរីយ៉ា ០៧នាក់ , ឥណ្ឌូនេស៊ី ០២នាក់ , រុស្ស៊ី ០២នាក់ រ៉ូម៉ានី ០២នាក់ ហូឡង់ ០១នាក់ ន័រវ៉េ ០២នាក់ ទួរគី ០១នាក់ និងម៉ាឡេស៊ី ០១នាក់ ។

– **គ្រឿងញៀនសរុប** ចាប់យកបានចំនួន **៤០៥** គ.ក្រ **១១២,១៦** ក្រាម (ធៀបនឹងឧសភា/២០១៨ **៥០៣** គ.ក្រ **៤៤០** ក្រាម) ថយចុះ **៩៨** គ.ក្រ **៣២៧,៨៤** ក្រាម ស្មើនឹង **១៩,៤៨** % ក្នុងនោះ ៖

- មេតំហ្វេតាមីនក្រាមម្សៅ (ICE) ១៥០ គ.ក្រ ៧៥១,៧២ ក្រាម
- មេតំហ្វេតាមីនគ្រាប់ (WY) ១៥ គ.ក្រ ៦៥៤,២៨ ក្រាម
- អិចស្តាស៊ី ៣៦ គ.ក្រ ៥៨៤,២៣ ក្រាម
- ហេរ៉ូអ៊ីន ២៤,៤៧ ក្រាម
- កូកាអ៊ីន ៦១០,៩៤ ក្រាម
- កេតាមីន ២៨ គ.ក្រ ២១៦,៥២ ក្រាម
- សារធាតុពីរ៉ូវ៉ាឡេរ៉ូន ១៧៣ គ.ក្រ ២៧០ ក្រាម

– **កញ្ឆាស្រស់** កាប់បំផ្លាញដើមកញ្ឆាបានចំនួន **៨៣.០៥៨** ដើម

– **កញ្ឆាក្រៀម** ចំនួន **២១៩** ក្រាម

– **សម្ភារចាប់យក** ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត រួមមាន ៖ រថយន្ត ៥៥គ្រឿង , ម៉ូតូ ២.០០៦គ្រឿង ,ទូរស័ព្ទ ៥.៣១២គ្រឿង , ជញ្ជីង ២៩២គ្រឿង ,អាវុធវែង៩ដើម , អាវុធខ្លី៦ដើម,ប្រាក់កម្ពុជា ៧២.៦១២.១០០រៀល,ប្រាក់អាមេរិក១២៧.៧១២ដុល្លារ , ប្រាក់ថៃ ៧៤.៤៨០បាត, ប្រាក់វៀតណាម ១៤.៩០៣.០០០ ដុង និងបង្គុកផ្ទះល្វែង០១កន្លែង ដី០១ឡូត៍ ។

2 ) បទល្មើស ជនសង្ស័យ វត្ថុតាងគ្រឿងញៀន ទ្រព្យសម្បត្តិ យកតាមតារាងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ជនសង្ស័យចាប់ខ្លួនតាមដីកាមាន ២១៤ដីកា ឃាត់ខ្លួនជនសង្ស័យ ២១១នាក់ (ស្រី០៨នាក់) ។

- ក្នុងឱកាសប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ អាជ្ញាធរជាតិបានដុតបំផ្លាញវត្ថុតាងគ្រឿងញៀន សារធាតុគីមីផ្សំ និងសារធាតុពាក់ព័ន្ធផ្សេងៗ តាមអំណាចសាលក្រម សាលដីកាស្ថាពររបស់សាលាដំបូងរាជធានីភ្នំពេញ ចំនួន **២ តោន ៣៦១ គីឡូក្រាម ៣៣៨,៤៦ ក្រាម និង ២២ ដប** ។

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល ៖

- អនុវត្តវិធានការរដ្ឋបាលបានចំនួន **១.៤៦៣ លើក** ក្នុងនោះ បានអញ្ជើញម្ចាស់អាជីវកម្ម និងអ្នកពាក់ព័ន្ធមកស្តាប់ការណែនាំចំនួន **១៦៥ លើក** ស្មើនឹង **៧.៣៥០ នាក់**/ស្រី ៣.៤៦៧ នាក់ និងចុះអប់រំម្ចាស់ទីតាំងអាជីវកម្មចំនួន **១.២៩៣ គោលដៅ (សណ្ឋាគារ០៨** ផ្ទះសំណាក់**១០៦** ផ្ទះជួល**៧២០** ភោជនីយដ្ឋាន**១២** ខារ៉ាអូខេ**១០៣ និង**ទីតាំងផ្សេងៗ**៣៣៤**កន្លែង**)**

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានចុះធ្វើតេស្តរកសារធាតុញៀនលើក្មេងទំនើង ជនមានតម្រុយប្រើប្រាស់គ្រឿងញៀន និងឆ្មក់ត្រួតពិនិត្យអ្នកបើកបរយានដឹកទំនិញ ដឹកកម្មករ ដឹកអ្នកដំណើរ បុគ្គលិកក្លឹបកម្សាន្ត កាស៊ីណូ សណ្ឋាគារ ខារ៉ាអូខេ សរុបចំនួន **៦០៥ លើក** ស្មើនឹង **៨.២៥៧ នាក់/ស្រី២០៨នាក់ រកឃើញអ្នកផ្ទុកសារធាតុញៀន ៩៤៤ នាក់** ត្រូវបានសមត្ថកិច្ចធ្វើការបញ្ជូនតាមនីតិវិធីច្បាប់ ឲ្យទៅទទួលយកសេវាបន្សាប និងព្យាបាល

- ការអនុវត្តវិធានការរដ្ឋបាល នៅតាមគោលដៅក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន យើងបានធ្វើបច្ចុប្បន្នភាពដោយតម្លើងបញ្ជីទីតាំងគោលដៅចំនួន**៨.៧០២ទីតាំង** និងបានធ្វើកិច្ចសន្យាជានាមិនឲ្យមានពាក់ព័ន្ធការជួញដូរ ការប្រើប្រាស់គ្រឿងញៀននៅទីតាំងអាជីវកម្មរបស់ខ្លួន បានចំនួន **៥.១៤៤ ទីតាំង** សម្រេចបាន ៥៩,១១ % នៅទូទាំងប្រទេស ។ ទន្ទឹមនោះ បានឆ្មក់ចូលត្រួតពិនិត្យរដ្ឋបាលផង និងឈានទៅអនុវត្តវិធានការផងចំពោះទីតាំងផ្ទះសំណាក់ ផ្ទះជួល ក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន ដែលមានសកម្មភាពជួញដូរ-ប្រើប្រាស់គ្រឿងញៀនបានចំនួន ២១ ទីតាំង ក្នុងនោះ បិទជាស្ថាពរចំនួន ០៧ ទីតាំង រួមមាន ក្លឹបកម្សាន្ត០៤ ទីតាំង និងខារ៉ាអូខេ ០៣ទីតាំង ។

### ៣.៤. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ៖

មន្ទីរពិសោធន៍គ្រឿងញៀន នៃ អ.ជ.ប.គ.ញ. បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀនបានចំនួន **៤.៤៩៧** សំណាក = **៤.០៤៣** ករណី ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន ៤.៣២៣** សំណាក (៩៦.៩៦៖ %) = **៣.៩៥៤** ករណី គឺ ៖
    - មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៣.៨១៧ សំណាក (៨៤,៨៧ %)
    - មេតំហ្វេតាមីនគ្រាប់ (WY) ១៦៤ សំណាក (៣,៦៤ %)
    - កេតាមីន ១៣៩ សំណាក(៣,០៩ %)
    - កូកាអ៊ីន ៣ សំណាក(០,០៦ %)
    - MDMA ១៥៩ សំណាក (៣,៥៣ %)
    - កញ្ឆា ៨ សំណាក (០,១៧ %)
    - សារធាតុញៀនប្រភេទ (2CB) ៣ សំណាក (០,០៦ %)
    - នីមេតាហ្សេប៉ាម ១៦ សំណាក(០,៣៥ %)

- អំហ្វេតាមីន ៣ សំណាក(០,០៦ %)
- ហេរ៉ូអ៊ីន ៤ សំណាក(០,០៨ %)
- សារធាតុញៀនប្រភេទពីរ៉ូវ៉ាឡេរ៉ូន ៧ សំណាក(០,១៥ %)

– **សំណាកអវិជ្ជមានសារធាតុញៀន ១៧៤** សំណាក = **៨៩** ករណី (៣,៨៦ %)

– ផ្តល់ដល់ស្ថាប័នអនុវត្តច្បាប់ រួមមានៈស្នងការដ្ឋាននគបាលរាជធានីភ្នំពេញ ខេត្តប៉ៃលិន ត្បូងឃ្មុំ កំពង់ចាម កំពង់ស្ពឺ កំពង់ធំ កំពត ស្វាយរៀង តាកែវ រតនគីរី បន្ទាយមានជ័យ ព្រះសីហនុ បាត់ដំបង កែប ព្រៃវែង និង ខេត្តកណ្តាល , បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស កងរាជអាវុធហត្ថខេត្តកណ្តាល និងរាជធានីភ្នំពេញ, នាយកដ្ឋានសន្តិសុខផ្ទៃក្នុង នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ និងកងទ័ពជើងគោកយោធភូមិភាគទី១ និងមន្ទីរប្រឆាំងគ្រឿងញៀន នូវស្រោមសំបុត្ររក្សាវត្ថុតាងគ្រឿងញៀន សរុបចំនួន ២.១២០ សន្លឹក ជញ្ជីងថ្លឹងថ្នាំញៀន០២ គ្រឿង តេស្តរកសារធាតុញៀន(ម៉ាគ្វីតេស្ត)ចំនួន ៦.៦៩០ តេស្ត កូកាអ៊ីនតេស្តចំនួន ១០០ តេស្ត កេតាមីនតេស្ត ចំនួន៤២៥ តេស្ត (ម៉ាគ្វីតេស្ត)ចំនួន ៥០០ មិល្លីលីត្រ (ស៊ីម៉ុនតេស្ត)ចំនួន ៤០០ មិល្លីលីត្រ និងតេស្តរកសារធាតុញៀនក្នុងទឹកមូត្រប្រភេទ ៖ (មេតំហ្វេតាមីន)ចំនួន ២៣.៦០០ តេស្ត (កេតាមីន)ចំនួន ២៨០តេស្ត (អិចស្តាស៊ី)ចំនួន ៣២០តេស្ត ។

### ៣.៥. ចំណាត់ការរឿងក្តីពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនរបស់រាជធានី-ខេត្ត ៖

– **សំណុំរឿងសរុបចំនួន ៥.៤៨៩ រឿង** រួមមានបទល្មើស ៖ ជួញដូរគ្រឿងញៀនចំនួន ៧៥៤ រឿង , ជួញដូរ និងប្រើប្រាស់គ្រឿងញៀនចំនួន ២០៦រឿង , ជួញដូរ និងរក្សាទុកគ្រឿងញៀនចំនួន ២.៥៣៤រឿង , រក្សាទុក និងប្រើប្រាស់សារធាតុញៀនខុសច្បាប់ចំនួន ៨០រឿង , ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀនចំនួន ២៣១រឿង , ចាត់ចែងឲ្យប្រើប្រាស់នូវគ្រឿងញៀនចំនួន ៥២៦រឿង , បទប្រើប្រាស់គ្រឿងញៀនចំនួន ៨៩១ រឿង និងបទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ២៦៧ រឿង ។

– **ជនល្មើសសរុបចំនួន ៧.៨៨៩ នាក់** រួមមានជនល្មើសជា ៖ នីតិជនចំនួន ៧.៣០៣ នាក់(ស្រី ៩៥៤នាក់) , អនីតិជនចំនួន ៥៨៦ នាក់(ស្រី៤៧នាក់) ក្នុងនោះ ៖

ជាមួយគ្នានេះ ក្រុមការងាររបស់ក្រសួងយុត្តិធម៌ និងគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន បាន ៖

– ចុះប្រមូលមធ្យោបាយពាក់ព័ន្ធនឹងវត្ថុតាងបទល្មើសគ្រឿងញៀន ដែលត្រូវរឹបអូសជាសម្បត្តិរដ្ឋ តាមសាលក្រមស្ថាពរ នៅសាលាដំបូងរាជធានីភ្នំពេញ ខេត្តព្រៃវែង កំពង់ធំ ស្វាយរៀង កោះកុង កំពង់ចាម ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បន្ទាយមានជ័យ និងខេត្តសៀមរាប រួមមាន ៖ រថយន្តចំនួន០២គ្រឿង និងម៉ូតូចំនួន ១៤០គ្រឿង

– ចុះអនុវត្តសាលដីកាព្រហ្មទណ្ឌលេខ ៩៣ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩របស់តុលាការកំពូល ដើម្បីរឹបអូសដីចំការទំហំ ៥៦៤.៣៧៧ ម៉ែត្រការ៉េ នៅភូមិបុស្សតាផង់ ឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ ផ្ទះ០១ល្វែង នៅសង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន និង០១ល្វែងទៀត នៅសង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ របស់ទណ្ឌិតឈ្មោះ កែវ សារឿន

– លក់ឡាយឡុងវត្ថុតាងផ្ទះវីឡាចំនួន០១កន្លែងស្ថិតនៅភូមិព្រែកប្រា សង្កាត់អូរអណ្តូង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ បានប្រាក់ចំនួន ៨៦០.០០០(ប្រាំបីរយហុកសិបពាន់)ដុល្លារអាមេរិក និងលក់ម៉ូតូចំនួន៨៧

គ្រឿងនៅសាលាដំបូងខេត្តកណ្តាល បានប្រាក់ចំនួន ១៤.៥១០(ដប់បួនពាន់ និងប្រាំរយដប់)ដុល្លារអាមេរិក

– ដុតបំផ្លាញគ្រឿងញៀនគ្រប់ប្រភេទ ដែលរឹបអូសបានរបស់សាលាដំបូងខេត្តស្ទឹងត្រែង ព្រះវិហារ រតនគិរី ក្រចេះ និងខេត្តមណ្ឌលគិរី សរុបចំនួន **១៩៣ គីឡូក្រាម និង៨៣៧,៣០ ក្រាម** ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យបង្កើនការយកចិត្តទុកដាក់គ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំ វត្ថុធាតុដើម ព្រមទាំងសារធាតុផ្សំផ្សេងទៀត ដើម្បីបង្ការ និងទប់ស្កាត់ការបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់ យើងបានរៀបចំលិខិតបទដ្ឋានគតិយុត្ត និងចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីផ្សំ ដូចខាងក្រោម ៖

**៤.១.** បានរៀបចំកែសម្រួលសមាសភាពក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ។

**៤.២.** បានរៀបចំសេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន។

**៤.៣.** បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំគ្រឿងញៀន ។

**៤.៤.** បានរៀបចំប្រជុំក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។

**៤.៥.** បានចូលរួមធ្វើបទបង្ហាញ ស្តីពីការគ្រប់គ្រងសារធាតុគីមីផ្សំគ្រឿងញៀនដល់សិប្បករ ឧស្សាហករ ក្រុមហ៊ុននាំចូលចែកចាយរោងចក្រប្រើប្រាស់សារធាតុគីមីផ្សំ នៅវិទ្យាស្ថានស្តង់ដាកម្ពុជា ។

**៤.៦.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការប្រមូលព័ត៌មាន និងត្រួតពិនិត្យឯកសារការអនុញ្ញាតឲ្យនាំចូលនូវសារធាតុញៀននិងសារធាតុគីមីផ្សំ ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជាក់ស្តែងរយៈពេល៩ខែ ឆ្នាំ២០១៩នេះ បាននាំចូលសរុបចំនួន **១២.៨៦៩.៤០៩** គ.ក្រ **០៩១** ក្រាម ក្នុងនោះ ៖

- ➢ តារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ៖

– ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានផ្តល់អាជ្ញាប័ណ្ណនាំចូល ឬចែកចាយសារធាតុគីមីផ្សំចំនួន **៧០.១៦៣.៨១០** គ.ក្រ **និង ៨៦.១៤៦** លីត្រ

– ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ផ្តល់អាជ្ញាប័ណ្ណនាំចូលសារធាតុគីមីផ្សំ ចំនួន ៨.១០៩.០០០ គ.ក្រ

– ក្រសួងសុខាភិបាលផ្តល់អាជ្ញាប័ណ្ណនាំចូលវត្ថុធាតុដើម និងឱសថ ចំនួន **១៥២** គ.ក្រ **៨២៧** ក្រាម

- ➢ តារាងទី២ និងទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ៖

ក្រសួងសុខាភិបាល បានផ្តល់អាជ្ញាប័ណ្ណនាំចូលសារធាតុញៀនក្នុងទម្រង់ជាវត្ថុធាតុដើម ចំនួន ៦០០ គ.ក្រ និងទម្រង់ជាសារធាតុផ្ទុកក្នុងឱសថ ចំនួន **៣៣** គ.ក្រ **២៦៤** ក្រាម ។

ជាមួយគ្នានេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បាន ៖

– ប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីស្តង់ដារកម្ពុជា ដោយបានបញ្ជ្រាបការងារត្រួតពិនិត្យគ្រឿងញៀន និងនីតិវិធីនៃការគ្រប់គ្រងសារធាតុគីមីផ្សំគ្រឿងញៀន ដល់សិប្បករ ឧស្សាហករ ក្រុមហ៊ុននាំចូល ចែកចាយ និងរោងចក្រប្រើប្រាស់សារធាតុគីមីផ្សំបានចំនួន០៦ខេត្ត មានអ្នកចូលរួម ៥៣១នាក់

– រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ ស្តីពីស្តង់ដារកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ ការនាំចេញ ការនាំចូល ការផ្គត់ផ្គង់ និងការស្តុកទុកសារធាតុគីមី និងសារធាតុគីមីជាប់ប្បញ្ញត្តិ ដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្ម នៅវិទ្យាស្ថានស្តង់ដារកម្ពុជា

– បញ្ចូលសារអប់រំក្នុងស្លាកផលិតផលនូវពាក្យស្លោក " គ្រឿងញៀននាំមកនូវគ្រោះថ្នាក់ដល់សុខភាព" បានចំនួន ៥១៨ ផលិតផល ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យបន្តអនុវត្តនូវរាល់កិច្ចការដែលបានព្រមព្រៀងគ្នាកន្លងមក ជាមួយភាគីថៃ ឡាវ និងវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ព្រមទាំងពង្រឹងការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គសម្រាប់ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ពិសេសការកសាងភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀននៅតាមបណ្តោយព្រំដែន ដែលភាគីកម្ពុជា ឡាវ ថៃ និងវៀតណាម បានឯកភាពគ្នា និងការពង្រឹងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន(ការិ.**BLO**) បន្ថែមទៀត នៅតាមព្រំដែនកម្ពុជា-ឡាវ កម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ក៏ដូចជាចំពោះមុខនេះ ណែនាំឲ្យខេត្ត-ក្រុងជាប់ព្រំដែន ត្រូវជ្រើសរើសឃុំ-សង្កាត់០១ក្នុងខេត្តក្រុង ដើម្បីអនុវត្តផែនការភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន ។ ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៩ នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចូលរួម និងសហការសម្របសម្រួលអនុវត្តយន្តការនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយប្រទេសឡាវ ថៃ និងវៀតណាម ដូចជាការចូលរួមកិច្ចប្រជុំ និងសិក្ខាសាលា ទាំងនៅក្នុង និងនៅក្រៅប្រទេសសរុបបានចំនួន **១៣** លើក **គឺ** ៖

- កិច្ចប្រជុំពិភាក្សាលើខ្លឹមសារនៃផែនការសហប្រតិបត្តិការ ឆ្នាំ២០១៩ រវាងក្រសួងមហាផ្ទៃ(កម្ពុជា) និងក្រសួងនគរបាលវៀតណាម នៅទីស្តីការក្រសួងមហាផ្ទៃ
- កិច្ចប្រជុំត្រៀមសម្រាប់រៀបចំកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ និងថ្នាក់រដ្ឋមន្ត្រី ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅទីក្រុងបាងកក ប្រទេសថៃ
- កិច្ចប្រជុំពិភាក្សាលើខ្លឹមសារសេចក្តីព្រាងកំណត់ហេតុ ស្តីពីកិច្ចសហប្រតិបត្តិការ ឆ្នាំ២០១៩ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅទីស្តីការក្រសួងមហាផ្ទៃ
- សិក្ខាសាលាអាស៊ាន ស្តីពីកិច្ចប្រតិបត្តិការបណ្តាញឃ្លាំមើលគ្រឿងញៀន លើកទី៧ និងលើកទី៨ នៅទីក្រុងបាងកក ប្រទេសថៃ
- កិច្ចប្រជុំគណៈកម្មការសម្របសម្រួលចម្រុះសម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម លើកទី១២ នៅខេត្តក្រចេះ ។
- សិក្ខាសាលា ស្តីពីការរៀបចំផែនការប្រតិបត្តិសុវត្ថិភាពទន្លេមេគង្គឆ្នាំ២០១៩ នៅប្រទេសថៃ
- សិក្ខាសាលា ស្តីពីវិធានការឆ្លើយតបប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន នៅប្រទេសថៃ
- សិក្ខាសាលា និងទស្សនកិច្ចសិក្សាស្តីពីភូមិ ស គ្មានគ្រឿងញៀននៅតាមព្រំដែន នៅប្រទេសថៃ
- សិក្ខាសាលា និងទស្សនកិច្ចសិក្សាអំពីការលើកកម្ពស់កម្មវិធីអភិវឌ្ឍន៍ដំណាំជំនួស នៅប្រទេសថៃ
- កិច្ចប្រជុំពិនិត្យឡើងវិញលើផែនការសហប្រតិបត្តិការអាស៊ានចំពោះដំណោះស្រាយការផលិតគ្រឿងញៀនខុសច្បាប់នៅតំបន់ត្រីកោណមាស សម្រាប់ឆ្នាំ២០១៧-២០១៩ នៅប្រទេសថៃ
- កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ស្តីពីការពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មគ្រឿងញៀនឆ្លងដែន ដែលរៀបចំដោយក្រសួងសន្តិសុខសាធារណៈសង្គមនិយមវៀតណាម និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីត្រីភាគី/ទ្វេភាគីកម្ពុជា-ឡាវ-វៀតណាមស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដែលរៀបចំដោយគណៈកម្មាធិការ អចិន្ត្រៃយ៍ទទួលផ្ទែកគ្រឿងញៀនវៀតណាម(SODC) នៅទីក្រុងហាណូយ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យបន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ អង្គការUNODCនិងគម្រោងសហប្រតិបត្តិការជាមួយ ការិយាល័យអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ក៏ដូចជាគម្រោងសុវត្ថិភាពទន្លេមេគង្គ(Safe Mekong Project) ពិសេសពង្រឹងប្រសិទ្ធភាពការិយាល័យទំនាក់ទំនងព្រំដែន(ការិ.BLO)។ ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៩ នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចូលរួម និងសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន តាមរយៈជំនួបពិភាក្សាការងារ ការចូលរួមកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា សរុបបានចំនួន **១០** លើក **គឺ** ៖

- ជំនួបពិភាក្សាការងារលើកិច្ចការត្រួតពិនិត្យគ្រឿងញៀន និងគម្រោងជំនួយមួយចំនួន ជាមួយគណៈប្រតិភូនៃស្នងការដ្ឋាននគរបាលខេត្តយូណាន(ប្រទេសចិន) គណៈប្រតិភូស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា និងគណៈប្រតិភូអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ.
- កិច្ចប្រជុំអន្តរក្រសួងស្តីពីការរៀបចំកិច្ចប្រជុំសហប្រធាននៃគណៈកម្មការអន្តររដ្ឋាភិបាល កម្ពុជា-រុស្ស៊ី នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ទស្សនៈកិច្ចសិក្សារបស់ក្រុមការងារយុត្តិធម៌អនីតិជន នៃក្រសួងយុត្តិធម៌ នៅប្រទេសNew Zealand
- ជំនួបពិភាក្សាការងារជាមួយគណៈប្រតិភូអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ កិច្ចសហប្រតិបត្តិការលើការងារអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីគ្រឿងញៀន គម្រោងជំនួយODA( Official Development Assistant )របស់សាធារណរដ្ឋកូរ៉េ
- សន្និសីទ ស្តីពីកិច្ចប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន (ADEC-24) លើកទី២៤ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក នៅទីក្រុងតូក្យូ ប្រទេសជប៉ុន
- កិច្ចប្រជុំគណៈកម្មការគ្រឿងញៀនអង្គការសហប្រជាជាតិ លើកទី៦២ នៅទីក្រុងវីយែន ប្រទេសអូទ្រីស ។
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងផែនការវេទិកាតំបន់អាស៊ានស្តីពីការប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន សម្រាប់ឆ្នាំ២០១៩-២០២១ នៅក្រសួងការបរទេសកម្ពុជា
- វគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យបទល្មើសគ្រឿងញៀន នៅប្រទេសជប៉ុន
- កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីបញ្ហាគ្រឿងញៀន នៅខេត្តសៀមរាប
- កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន( ADLOMICO )លើកទី២៩ នៅប្រទេសកូរ៉េ ។

**ដោយឡែក ពាក់ព័ន្ធនឹងសកម្មភាពការងារនៃកិច្ចសហប្រតិបត្តិការអន្តរជាតិមួយចំនួនទៀត មានចែងលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធ ។**

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យជំរុញការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយផ្តោតធ្វើយ៉ាងណាឲ្យគណៈកម្មការ ការតាមដានការប្រមូល ការគ្រប់គ្រងនិងការចាត់ចែងទ្រព្យដែលពាក់ព័ន្ធបទល្មើសគ្រឿងញៀន មានសិទ្ធិចេញសេចក្តីសម្រេចឲ្យលក់ ឬដួលអចលនទ្រព្យ មុនមាន

សាលក្រមស្ថាពររបស់តុលាការ ហើយថវិកាដែលទទួលបានពីការលក់ ឬជួលនេះ ត្រូវរក្សាទុកក្នុងគណនីរបស់គណៈកម្មការ ។ ត្រូវផ្តោតផងដែរលើនីតិវិធីក្នុងការសម្របសម្រួលឲ្យជនរងគ្រោះដោយសារគ្រឿងញៀន បានទៅទទួលយកសេវាព្យាបាលដោយមានភាពងាយស្រួលជាងមុន ពិសេសអាជ្ញាធរមូលដ្ឋានគួរមានសិទ្ធិរៀបចំចាត់ចែងការងារនេះ ។ បន្តរៀបចំបញ្ចូលសមាសភាពរបស់គណៈកម្មការភូមិ ឃុំ-សង្កាត់ ស គ្មានគ្រឿងញៀន និងគណៈកម្មការសម្របសម្រួលការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមឃុំ-សង្កាត់ ទៅក្នុងសមាសភាពគណៈកម្មការដឹកនាំ និងអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពនៅគ្រប់លំដាប់ថ្នាក់ ការពង្រឹងយន្តការសេនាធិការដើម្បីអនុវត្ត និងដឹកនាំការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនទាំងនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងការរៀបចំផែនការជាតិ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន យើងបានពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមរយៈ ៖

**៧.១.** បានបន្តដឹកនាំគណៈកម្មការទាំង៦ និងអនុគណៈកម្មការទាំង៣ នៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៤ ព្រមទាំងបានធ្វើបច្ចុប្បន្នភាពលើផែនការសកម្មភាព សម្រាប់ការអនុវត្តផែនការនេះ។

**៧.២.** បានបន្តនីតិវិធីពិនិត្យលើសេចក្តីព្រាងផែនការជាតិ៥ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន(២០១៩-២០២៣) ដើម្បីទទួលបានការអនុម័តពីរាជរដ្ឋាភិបាលក្នុងពេលខាងមុខ ។

**៧.៣.** បានរៀបចំកែសម្រួលសមាសភាពក្រុមលេខា និងក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ។

**៧.៤.** បាន និងកំពុងបន្តនីតិវិធីពិនិត្យ និងកែសម្រួលជាមួយក្រសួងយុត្តិធម៌ លើសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយផ្តោតធ្វើយ៉ាងណាឲ្យគណៈកម្មការ ការតាមដានការប្រមូល ការគ្រប់គ្រងនិងការចាត់ ចែងទ្រព្យដែលពាក់ព័ន្ធបទល្មើសគ្រឿងញៀន មានសិទ្ធិចេញសេចក្តីសម្រេចឲ្យលក់ ឬជួលអចលនទ្រព្យ មុនមានសាលក្រមស្ថាពររបស់តុលាការ ហើយថវិកាដែលទទួលបានពីពីការលក់ ឬជួលនេះ ត្រូវរក្សាទុកក្នុងគណនីរបស់គណៈកម្មការ ។ ត្រូវផ្តោតផងដែរលើនីតិវិធីក្នុងការសម្របសម្រួលឲ្យជនរងគ្រោះដោយសារគ្រឿងញៀន បានទៅទទួលយកសេវាព្យាបាលដោយមានភាពងាយស្រួលជាងមុន ពិសេសអាជ្ញាធរមូលដ្ឋានគួរមានសិទ្ធិរៀបចំចាត់ចែងការងារនេះ ។

**៧.៥.** បាន និងកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ សម្រាប់ការរៀបចំបង្កើតភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន ។

**ដោយឡែក ពាក់ព័ន្ធនឹងសកម្មភាពការងារនៃការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមួយចំនួនទៀត មានចែងលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធ ។**

## ៨. មូលនិធិជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ចាប់ពីពេលបង្កើតមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានកៀរគរ និងប្រមូលបានមូលនិធិសរុបចំនួន **៥.១៣២.៣២៣** ដុល្លារ(ប្រាំលានមួយរយសាមសិបពីរពាន់ និងបីរយម្ភៃបីដុល្លារអាមេរិក) ដែលថវិកានេះបានមកពីការចូលរួមរបស់សប្បុរសជន តាមរយៈមូលនិធិជួយសង្គ្រោះអ្នកញៀនគ្រឿងញៀនរបស់**សម្តេចក្រឡាហោម** ចំនួន **៣២៩.៩២៨** ដុល្លារ(បីរយម្ភៃប្រាំបួនពាន់ និងប្រាំបួនរយម្ភៃ

ប្រាំបីដុល្លារអាមេរិក) ការលក់ទ្រព្យសម្បត្តិដែលបានមកពីការរឹបអូសដីនិងផ្ទះ២កន្លែងចំនួន**១.៨០២.៣៩៥**ដុល្លារ (មួយលានប្រាំបីរយពីរពាន់ និងបីរយកៅសិបប្រាំដុល្លារអាមេរិក) និងជំនួយឥតសំណងរបស់រដ្ឋាភិបាលវៀតណាម ចំនួន៣លានដុល្លារអាមេរិក(បីលានដុល្លារអាមេរិក) សម្រាប់ការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ ។ ជាមួយគ្នានេះ កាលពីក្នុងអំឡុងឆ្នាំ២០១៧ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ក៏បានផ្តល់ជំនួយក្នុងទឹកប្រាក់ចំនួន **១.១៥៥.៣៦១** ដុល្លារអាមេរិក សម្រាប់ការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀនផងដែរ មូលនិធិខាងលើត្រូវបានប្រើប្រាស់សម្រាប់ ៖

- ការកសាងមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
- ការផ្តល់ការលើកសរសើរដល់មន្ត្រីអនុវត្តច្បាប់ និងការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀន ។

ជាមួយគ្នានេះអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានជម្រុញឲ្យក្រសួងយុត្តិធម៌ អន្តរាគមន៍ដល់ស្ថាប័នអយ្យការ និងតុលាការគ្រប់ជាន់ថ្នាក់ ឲ្យខិតខំប្រមូល និងគ្រប់គ្រងទ្រព្យសម្បត្តិ មធ្យោបាយ និងសម្ភារដែលជាកម្មវត្ថុនៃការចាប់យក និងរឹបអូសក្នុងបទល្មើសគ្រឿងញៀន ដើម្បីប្រគល់ជូនគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនឲ្យបានទាន់ពេលវេលា និងឈានទៅចាត់ចែងមូលនិធិឲ្យមានប្រសិទ្ធភាពខ្ពស់ ។

## IV. ការសន្និដ្ឋាន និងវាយតម្លៃ

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖

**ចំណុចខ្លាំង ៖**

- គណៈកម្មការទទួលបន្ទុកអប់រំផ្សព្វផ្សាយនៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ បានរៀបចំឲ្យមានផែនការសកម្មភាពជាក់លាក់ និងមានលក្ខណៈពហុវិស័យ សម្រាប់ការបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនប្រកបដោយគុណភាពទៅក្នុងគ្រប់វេទិកា និងព្រឹត្តការណ៍ផ្សេងៗក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត ដើម្បីធានាបាននូវការយកចិត្តទុកដាក់អនុវត្តយ៉ាងសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់
- ជនបង្គោលដែលបានបណ្តុះបណ្តាល ពួកគាត់បានចូលរួមធ្វើសកម្មភាពអប់រំផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀនយ៉ាងផុលផុស
- ទទួលបានការចូលរួម និងគាំទ្រពីគ្រប់មជ្ឈដ្ឋានសង្គម ពិសេសពីស្ថាប័នជាតិសំខាន់ៗ ដូចជា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល កាកបាទក្រហមកម្ពុជា ក៏ដូចជាការចូលរួម និងគាំទ្រពីវិស័យសាសនា វិស័យឯកជន មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ លោកគ្រូ-អ្នកគ្រូ និស្សិត សិស្សានុសិស្ស ប្រព័ន្ធផ្សព្វផ្សាយវិទ្យុ ទូរទស្សន៍ ប្រព័ន្ធទំនាក់ទំនងសង្គម រួមផ្សំជាមួយនឹងការចូលរួម និងគាំទ្រកាន់តែសកម្ម និងផុលផុសពីសំណាក់ប្រជាពលរដ្ឋ ពិសេសនៅក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ សំដៅកាត់បន្ថយបទល្មើសគ្រឿងញៀន និងការពារបានសុខុមាលភាពសង្គម ។

**ចំណុចខ្វះខាត ៖**

- ក្រសួង-ស្ថាប័ន អង្គភាព ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត(ដែលរួមមានយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ក្រុង ស្រុក)មួយចំនួន នៅមិនទាន់ប្រើប្រាស់ឲ្យអស់ពីលទ្ធភាព និងការទទួលខុសត្រូវ

អនុវត្តឲ្យបានសកម្មនូវរាល់កិច្ចការដែលបានកំណត់ក្នុងផែនការសកម្មភាពនៃយុទ្ធនាការលើកទី៤នេះ

– ក្រសួង-ស្ថាប័ន អង្គភាព ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តខ្លះទៀត បានចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធទាំងគ្រឿងញៀនខុសច្បាប់ លើកទី៤ បានសកម្មហើយ ប៉ុន្តែមិនបានផ្ញើរបាយការណ៍មកលេខាធិការដ្ឋាននៃយុទ្ធនាការឲ្យបានទៀងទាត់

– ក្រុមគោលដៅដែលប្រឈមខ្ពស់ ដូចជា ពលករចល័ត ពលករចំណាកស្រុក កម្មករសំណង់ កម្មកររោងចក្រ អ្នកបើកបររថយន្តដឹកជញ្ជូន អ្នកបម្រើសេវាកម្សាន្តសប្បាយ សិស្សគេចសាលា សិស្សបោះបង់ការសិក្សា នៅតែជាក្រុមគោលដៅដែលទទួលបានសារអប់រំផ្សព្វផ្សាយតិចជាងគេ ។ ជាមួយគ្នានេះ ការបណ្តុះបណ្តាល និងការចាត់តាំង ចងក្រងក្រុមជនបង្គោលសម្រាប់ការអប់រំផ្សព្វផ្សាយ ក៏មិនទាន់គ្រប់គ្រាន់តាមស្ថានភាពនៃក្រុមគោលដៅ និងមុខសញ្ញាប្រឈម ដូចជា នៅតាមផ្ទះសំណាក់ ផ្ទះជួល ក្លឹបកម្សាន្ត ក៏ដូចជានៅតាមមូលដ្ឋានផលិតកម្មក្រៅប្រព័ន្ធ(ស្វ័យនិយោជន) ។ល។ ឱ្យបានជាក់ស្តែងនៅឡើយ

– រដ្ឋបាលមូលដ្ឋានឃុំ-សង្កាត់ ក៏ដូចជាបណ្តាអង្គភាពពាក់ព័ន្ធនៅក្នុងមូលដ្ឋាន នៅតែមិនទាន់ទទួលខុសត្រូវដើរតួជាកម្លាំងជួរមុខក្នុងការបង្ការទប់ស្កាត់ និងដោះស្រាយរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន នៅក្នុងមូលដ្ឋានរបស់ខ្លួន ហើយភាគច្រើនពឹងផ្អែកតែទៅលើកិច្ចអន្តរាគមន៍ពីសមត្ថកិច្ចថ្នាក់លើ ។

**២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖**

**ចំណុចខ្លាំង ៖**

– គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន បានពង្រឹងនិងពង្រីកការងារព្យាបាល និងលើកកម្ពស់សមត្ថភាពមន្ត្រីរបស់ខ្លួនពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន

– ការត្រៀមដាក់ឲ្យដំណើរការមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅខេត្តព្រះសីហនុ ដើម្បីអាចទទួលយកជនរងគ្រោះដោយសារគ្រឿងញៀនជាលើកដំបូង នាចុងឆ្នាំ២០១៩

– កិច្ចសហការកាន់តែល្អប្រសើររវាងក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ពិសេសរវាងអង្គភាពអនុវត្តច្បាប់ ព្រះរាជអាជ្ញា តុលាការ និងមូលដ្ឋានផ្តល់សេវាសុខភាព

– ការកើនឡើងនូវការយល់ដឹង និងភ្ញាក់រលឹករបស់ប្រជាពលរដ្ឋ ក្នុងការបញ្ជូនកូនចៅដែលប្រើប្រាស់ ឬញៀនគ្រឿងញៀនឲ្យទៅទទួលយកសេវាព្យាបាល និងស្តារនីតិសម្បទា ។

**ចំណុចខ្វះខាត ៖**

– អ្នកញៀនគ្រឿងញៀនមួយចំនួន នៅមិនទាន់ភ្ញាក់រលឹកស្ម័គ្រចិត្តទៅទទួលសេវាព្យាបាល និងស្តារនីតិសម្បទា ដែលបញ្ហានេះអាចបណ្តាលមកពីការខ្មាស់អៀន និងខ្លាចការរើសអើង ឬការមិនយល់ដឹងច្បាស់លាស់ពីការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទា

– យន្តការនៃការធ្វើសមាហរណកម្ម ក៏ដូចជាការថែរទាំបន្តអ្នកដែលបានជាសះស្បើយពីគ្រឿងញៀន នៅមិនទាន់បានយកចិត្តទុកដាក់រៀបចំ និងបង្កើតឲ្យបានគ្រប់គ្រាន់នៅឡើយ ។ ទន្ទឹមនោះ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបំណិនជីវិត ដល់អ្នកទាំងនោះនៅមិនទាន់ឆ្លើយតបទៅតាមតម្រូវការទីផ្សារការងារក្នុងពេលបច្ចុប្បន្ន

– ការរៀបចំទិន្នន័យអ្នកញៀនគ្រឿងញៀនមិនមានលក្ខណៈជាប្រព័ន្ធ មិនស៊ីសង្វាក់គ្នារវាងក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ហើយការប្រមូល វិភាគ រក្សាទុក និងបញ្ជូនទិន្នន័យអ្នកញៀនគ្រឿងញៀន នៅមិនទាន់មានវិធីសាស្ត្រច្បាស់លាស់ និងឯកភាពគ្នានៅឡើយ ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ ៖**

**ចំណុចខ្លាំង ៖**

– គណៈកម្មការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនខុសច្បាប់តាមច្រកនៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ បានចង្អុលដឹកនាំដល់អនុគណៈកម្មការចំនួន៣ គឺ១-ទទួលបន្ទុកទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមច្រកព្រំដែនកម្ពុជា-ឡាវ ២-ទទួលបន្ទុកទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមច្រកអាកាសយានដ្ឋាន កំពង់ផែ និងច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារព្រំដែនទ្វេភាគី និង៣-ទទួលបន្ទុកទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបញ្ញើប្រៃសណីយ៍។ ព្រមជាមួយនោះ មន្ត្រីអនុវត្តច្បាប់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលបាននូវការគាំទ្រជាថវិកាផ្ដល់រង្វាន់ និងការសរសើរលើកទឹកចិត្តតាមគ្រប់រូបភាព ពីគណៈបញ្ជាការនៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់

– ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់របស់រាជរដ្ឋាភិបាល បានជះឥទ្ធិពលជាវិជ្ជមានធ្វើឲ្យបទល្មើសទូទៅមានការថយចុះ ជាពិសេសបទល្មើសព្រហ្មទណ្ឌមានការថយចុះគួរកត់សម្គាល់

– ការបណ្ដុះបណ្ដាលជំនាញ គួបផ្សំនឹងការអនុវត្តជាក់ស្ដែង រួមជាមួយការប្រើប្រាស់កម្លាំងសរុប ធ្វើឲ្យការស្រាវជ្រាវស៊ើបអង្កេតបទល្មើសកាន់តែមានប្រសិទ្ធភាព ។ ជាមួយគ្នានេះ តាមរយៈកិច្ចសហការផ្ដល់ព័ត៌មានរហ័សឲ្យគ្នាទៅវិញទៅមកជាមួយប្រទេសជិតខាង និងស្ថាប័នអន្តរជាតិបានល្អ ធ្វើឲ្យសមត្ថកិច្ចទប់ស្កាត់ និងបង្ក្រាបបទល្មើសបានច្រើនករណីធំៗ

– ការបើកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនជាទ្រង់ទ្រាយធំនៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន បានផ្ដល់នូវបទពិសោធន៍ល្អៗក្នុងការបង្រ្កមទីផ្សារជួញដូរ និងប្រើប្រាស់គ្រឿងញៀននៅផ្ទៃក្នុងប្រទេស ហើយក៏ជាសក្ខីកម្មឆ្លុះបញ្ចាំងអំពីឆន្ទៈមុតស្រួចរបស់កម្លាំងអនុវត្តច្បាប់ និងការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ប្រជាពលរដ្ឋ

– រាជធានី-ខេត្តទាំង២៥ បានតម្លើងបញ្ជីគ្រប់គ្រងទីតាំងគោលដៅអាជីវកម្មក្លឹបកម្សាន្ត ទីតាំងសប្បាយដ្ឋាននៅទូទាំងប្រទេស និងបានធ្វើកិច្ចសន្យាសហការលុបបំបាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ។

**បញ្ហាប្រឈម ៖**

– ឧក្រិដ្ឋជនអន្តរជាតិ នៅតែព្យាយាមប៉ុនប៉ងប្រើប្រាស់កម្ពុជា ធ្វើជាប្រទេសផលិតកែច្នៃ និងឆ្លងកាត់គ្រឿងញៀនខុសច្បាប់តាមគ្រប់រូបភាព ទាំងផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស និងបញ្ញើប្រៃសណីយ៍

– បណ្ដាខេត្តជាប់ព្រំដែន ពិសេសនៅភាគឦសានប្រទេស នៅតែជាខេត្តដែលបន្តមានសកម្មភាពចរាចរឆ្លងកាត់គ្រឿងញៀនខុសច្បាប់ ទោះបីបង្ក្រាបបានចំករណីធំៗ និងកាត់ផ្ដាច់ខ្សែរយៈទាក់ទងជាច្រើនហើយក៏ដោយ ។

**ចំណុចខ្វះខាត ៖**

–ការគ្រប់គ្រងគោលដៅភូមិសាស្ត្រ និងមុខសញ្ញាដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនមិនបានហ្មត់ចត់

–ការជួញដូរ ការប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមានឡើងនៅតាមទីតាំងមួយចំនួនដូចជា ផ្ទះសំណាក់ ផ្ទះជួល អាជីវកម្ម សេវាកម្មកម្សាន្ត និងតំបន់ស្មុគស្មាញមួយចំនួន ។ គោលដៅដែលកើតបទល្មើសគ្រឿងញៀន គឺជាគោលដៅដដែលៗ អាចបណ្ដាលមកពីការញញើតញញើម ឬមានផលប្រយោជន៍ ដែលនាំឱ្យការងារអនុវត្តច្បាប់មិនមានប្រសិទ្ធភាព

–វិធានការបង្អក រឹបអូស និងលក់ទ្រព្យដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន នៅតែមានភាពយឺតយ៉ាវ មិនឆ្លើយតបទៅនឹងសំណូមពររបស់មូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

–កិច្ចប្រតិបត្តិការវាយឆ្មក់ និងការដេកពិសោធន៍ការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់នៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋានដែលមានការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ទើបអនុវត្តបានលើ០៦ទីតាំង ក្នុង ០៣រាជធានី-ខេត្ត(រាជធានីភ្នំពេញ បន្ទាយមានជ័យ និងខេត្តសៀមរាប) ប៉ុណ្ណោះ។

– ការធ្វើកិច្ចសន្យាសហការលុបបំបាត់ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន នៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាននៅទូទាំងប្រទេស ទើបសម្រេចបានចំនួន**៣.៧៤១ទីតាំង/៧.១១៣ទីតាំង** ស្មើ ៥២ %ប៉ុណ្ណោះ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖**

**ចំណុចខ្លាំង ៖**

ដោយមានកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ យើងគ្រប់គ្រងបានជាប់ជាប្រចាំនូវទិន្នន័យសារធាតុគីមីផ្សំដែលមានការអនុញ្ញាតឲ្យនាំចូល និងតាមរយៈការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តច្បាប់ យើងកាន់តែមានបទពិសោធន៍ក្នុងការបង្ការ ទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំ ពីដំនួញស្របច្បាប់យកទៅសំយោគផលិតជាគ្រឿងញៀនខុសច្បាប់ ។

**ចំណុចខ្វះខាត ៖**

–ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យសារធាតុគីមីផ្សំដល់សមត្ថកិច្ចពាក់ព័ន្ធ និងបុគ្គលិកក្រុមហ៊ុនឧស្សាហកម្មគីមី នៅមិនទាន់ធ្វើបានទូលំទូលាយនៅឡើយ

–ការធ្វើសន្និធិត្រួតពិនិត្យសារធាតុគីមីផ្សំដែលប្រើប្រាស់ដោយក្រុមហ៊ុន រោងចក្រ សហគ្រាសក្នុងស្រុក នៅមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖**

**ចំណុចខ្លាំង ៖**

កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងយន្តការនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ជាមួយបណ្តាប្រទេសជាប់ព្រំដែន តាមរយៈការអនុវត្តតាមកំណត់ហេតុកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ផែនការសកម្មភាពក្នុងក្របខ័ណ្ឌសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដែលក្នុងនោះ មានសកម្មភាពមួយចំនួនត្រូវបានកំណត់ជាអាទិភាព ៖

– ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីអនុវត្តច្បាប់នៅទូទាំងប្រទេស

– ការផ្តល់មធ្យោបាយ សម្ភារ បរិក្ខារចាំបាច់មួយចំនួន ជួយសម្រួលដល់សេចក្តីត្រូវការចំពោះមុខ និងការផ្តល់ថវិកាដើម្បីទ្រទ្រង់សកម្មភាពអាទិភាពក្នុងកិច្ចការត្រួតពិនិត្យគ្រឿងញៀន

– ការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកទាក់ទងនឹងបទល្មើសគ្រឿងញៀន ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការត្រីភាគី និងទ្វេភាគី បានធ្វើឡើងយ៉ាងសកម្មនិងផុលផុស ដើម្បីឈានទៅទប់ស្កាត់ និងបង្ក្រាបទាន់ពេលនូវករណីជួញដូរគ្រឿងញៀនឆ្លងកាត់ព្រំដែន

– យើងបានឯកភាពគ្នាជាមួយភាគីឡាវ ថៃ និងវៀតណាម ដើម្បីរៀបចំបង្កើត" ភូមិ-ឃុំ/សង្កាត់ សគ្មានគ្រឿងញៀន" នៅតំបន់ព្រំដែនកម្ពុជា-ឡាវ កម្ពុជា-ថៃ និងកម្ពុជា -វៀតណាម

– យកចិត្តទុកដាក់ក្នុងការពង្រឹង និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន(BLO)បន្ថែមទៀត នៅតំបន់ដែលទទួលរងការគំរាមកំហែងពីគ្រឿងញៀន

**ចំណុចខ្វះខាត៖**

ទោះបីជាយើងបានសហការជាមួយប្រទេសជិតខាងទទួលបានលទ្ធផលជាច្រើនក៏ពិតមែន ប៉ុន្តែការជួញដូរគ្រឿងញៀនឆ្លងកាត់ព្រំដែនប្រទេសកម្ពុជា ទៅកាន់ទីផ្សារគ្រឿងញៀនខុសច្បាប់ក្នុងតំបន់ និងពិភពលោកនៅតែបន្តកើតមាន។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

**ចំណុចខ្លាំង ៖**

កម្ពុជាបានប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមជាមួយសហគមន៍អន្តរជាតិ ក្នុងការតស៊ូប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន តាមរយៈការគាំទ្រ និងចូលរួមអនុវត្តផែនការសកម្មភាពនានា រួមមាន៖

– ក្នុងក្របខ័ណ្ឌអាស៊ាន មហាអនុតំបន់ទន្លេមេគង្គ ក្រោមការសម្របសម្រួលរបស់អង្គការ UNODC

– ការអនុវត្តផែនការយុទ្ធសាស្ត្រនៃគម្រោងសុវត្ថិភាពទន្លេមេគង្គ និងមេគង្គក្រោម ដែលសម្របសម្រួលដោយប្រទេសថៃ

– ការអនុវត្តផែនការសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានានៅក្នុងតំបន់ និងពិភពលោក រួមទាំងជាមួយដៃគូអង្គការ និងភ្នាក់ងារអន្តរជាតិ ដូចជា អង្គការUNODC នគរបាលសហព័ន្ធអូស្ត្រាលី(AFP) រដ្ឋបាលបង្ក្រាបគ្រឿងញៀនសហរដ្ឋអាមេរិក(DEA) អគ្គរដ្ឋអាជ្ញាកូរ៉េ(SPO)។ល។ ជាលទ្ធផល សមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់កម្ពុជាកំពុងដើរតួនាទីយ៉ាងសកម្ម និងបានរួមចំណែកជាមួយបណ្តាប្រទេសនៅក្នុងតំបន់ និងពិភពលោកលើការងារតស៊ូបង្ក្រាបបណ្តាញអង្គការចាត់តាំងឧក្រិដ្ឋកម្ម ឈានទៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនពីតំបន់ផលិត និងកាត់បន្ថយឲ្យបានជាអតិបរិមានូវគ្រឿងញៀនក្នុងបណ្តាប្រទេសដែលមានតម្រូវការខ្ពស់ ។

**ចំណុចខ្វះខាត៖**

ទោះបីយើងបានធ្វើសកម្មភាពលេចធ្លោដូចបានជម្រាបជូនខាងលើក្តី តែការជួយគាំទ្រជាថវិកា មធ្យោបាយ និងសម្ភារពីបណ្តាប្រទេសផ្តល់ជំនួយ ក៏ដូចជាដៃគូអភិវឌ្ឍន៍នានាលើសកម្មភាពត្រួតពិនិត្យគ្រឿងញៀន បានកាត់បន្ថយមកនៅក្នុងកម្រិតតិចតួចបំផុត ដែលទាំងអស់នេះបានជះឥទ្ធិពលមិនល្អ និងធ្វើឲ្យសកម្មភាពត្រួតពិនិត្យគ្រឿងញៀនមានភាពអសកម្មដោយអន្លើ ទាំងនៅកម្ពុជា និងក្នុងតំបន់ទាំងមូល ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖**

**ចំណុចខ្លាំង ៖**

– ការបន្តដាក់ចេញនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបន្តពុះពារលុបបំបាត់គ្រឿងញៀននៅកម្ពុជា ដោយទទួលបាននូវការគាំទ្រ និងវាយតម្លៃខ្ពស់ពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ

– យន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានស្រាប់បានដំណើរការងារប្រកបដោយឆន្ទៈមោះមុត និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការចាត់តាំងដឹកនាំអនុវត្តផែនការសកម្មភាពទៅតាមសមត្ថកិច្ចរៀងៗខ្លួន ជាពិសេសការអនុវត្តនូវវិធានការទាំង**៥** នៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ធ្វើឲ្យទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់។

**ចំណុចខ្វះខាត ៖**

– យន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ក្រោមជាតិមួយចំនួន អនុវត្តមិនទាន់បានជាលក្ខណៈពហុវិស័យ

– គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ឃុំ/សង្កាត់ទូទាំងប្រទេស នៅពុំទាន់បានបង្កើតឲ្យបានពេញលេញ

–ការជំរុញលើកទឹកចិត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្របតាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពនៅមានកម្រិត

– ច្បាប់ ស្តីពីវិសោធន៍កម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន កំពុងស្ថិតក្នុងនីតិវិធីក្រសួងជំនាញ ។

– ផែនការជាតិ០៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន កំពុងស្ថិតក្នុងនីតិវិធីឆ្លង ។

– ការរៀបចំបញ្ចូលគណៈកម្មការសម្របសម្រួលការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅថ្នាក់ឃុំ/សង្កាត់ ទៅក្នុងសមាសភាពគណៈកម្មការដឹកនាំ និងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពនៅគ្រប់លំដាប់ថ្នាក់ នៅមានភាពយឺតយ៉ាវ ។

## V. ផែនការសកម្មភាពអនុវត្តទិសដៅការងារ ត្រីមាសទី៤ ឆ្នាំ២០១៩(ទិសដៅការងារលម្អិតផ្សេងទៀតមាននៅក្នុងឯកសារឧបសម្ព័ន្ធ)

ផ្អែកលើការសន្និដ្ឋានវាយតម្លៃ និងលទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដាក់ចេញទិសដៅសម្រាប់អនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ ដូចខាងក្រោម ៖

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖

**១.១.** បន្តការអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាសាធារណៈ ពីគ្រោះថ្នាក់នៃគ្រឿងញៀនដល់ក្រុមគោលដៅប្រឈម និងងាយប្រឈមនឹងគ្រោះថ្នាក់ ដូចជា ក្រុមយុវវ័យ ពលករចល័ត ពលករចំណាកស្រុក កម្មករសំណង់ កម្មកររោងចក្រ កម្មករក្រៅប្រព័ន្ធ អ្នកបើកបររថយន្តដឹកទំនិញ និងដឹកអ្នកដំណើរ អ្នកបំរើការងារនៅតាមសេវាកម្សាន្តសប្បាយ ។ល។

**១.២.** បន្តរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយ តាមរយៈការចុះចែកខិតប័ណ្ណ កូនសៀវភៅអប់រំ និងការបិទផ្ទាំងរូបភាព ពិសេសបោះពុម្ព និងផ្សព្វផ្សាយទិសស្លោករបស់**សម្តេចក្រឡាហោម ស ខេង** កុំ៣ ១រាយការណ៍ គឺ ៖ ១-កុំឲ្យពាក់ព័ន្ធ ២-កុំលើកលែង ៣-កុំអន្តរាគមន៍ និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន នៅតាមគោលដៅគ្រឹះស្ថាន សិក្សា រោងចក្រ សហគ្រាស ការដ្ឋានសំណង់ កសិដ្ឋាន លំនៅដ្ឋានកម្មករ និងលើយានយន្ត។ល។

**១.៣.** បន្តបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនប្រកបដោយគុណភាព នៅក្នុងកម្មវិធីប្រគុំតន្ត្រី ការផ្សព្វផ្សាយពាណិជ្ជកម្ម កម្មវិធីបុណ្យជាតិ និងអន្តជាតិធំៗ។ល។ និងនៅគ្រប់វេទិកា និងព្រឹត្តការណ៍ផ្សេងៗក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ។

**១.៤.** រៀបចំឲ្យមានខ្លឹមសារហាមឃាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់សណ្ឋាគារ ផ្ទះសំណាក់។ល។ និងជម្រុញឲ្យដាក់សារអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀននៅគ្រប់ផលិតផល ។

**១.៥.** បន្តបើកវគ្គបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋានអំពីគ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់មេឃុំ/ចៅសង្កាត់ នាយនគរបាលប៉ុស្តិ៍រដ្ឋបាល និងមន្ត្រីទទួលបន្ទុកការងារត្រួតពិនិត្យគ្រឿងញៀននៅតាមឃុំ/សង្កាត់ ។

**១.៦.** សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំទីកន្លែងអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀនស្របតាមគោលនយោបាយជាតិ ស្តីពីសុខភាពសិក្សា សម្រាប់ថ្នាក់ជាតិឲ្យបាន០១កន្លែងនៅរាជធានីភ្នំពេញ និងនៅតាមគ្រឹះស្ថានមធ្យមសិក្សា និងឧត្តមសិក្សាទូទាំងប្រទេស ។

**១.៧.** គាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ផលិតឧបទ្ទេសសិក្សា ដូចជា សៀវភៅសិក្សាគោល ស្តីពីគ្រឿងញៀន និងសុវត្ថិភាពនៃការអភិវឌ្ឍ សៀវភៅ ស្តីពីវិធីសាស្ត្រនៃការបង្រៀន និងការបណ្តុះបណ្តាលគ្រូបង្រៀន

នៅតាមគ្រឹះស្ថានគរុកោសល្យខេត្ត និងវិទ្យាស្ថានបណ្ដុះបណ្ដាលគ្រូ ។

**១.៨.** រៀបចំសិក្ខាសាលាស្ដីពីការងារផ្សព្វផ្សាយអប់រំ ដើម្បីលើកកម្ពស់ការងារផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនឱ្យកាន់តែមានសុក្រឹត្យភាព និងប្រសិទ្ធភាពក្នុងពេលខាងមុខ ។

**១.៩.** ត្រៀមដឹកនាំ និងសម្របសម្រួលធ្វើសកម្មភាពអប់រំផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀននៅក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ អកអំបុក ។

**១.១០.** បន្តបញ្ជូនសារអប់រំផ្សព្វផ្សាយតាមទូរស័ព្ទចល័ត តាមគេហទំព័រ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**១.១១.** បន្តបញ្ចូលសកម្មភាពអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងផែនការនារីរតនៈទី៥(២០១៩-២០២៣)។

**១.១២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. នឹងដើរតួជាអ្នកសម្របសម្រួល ដើម្បីធានាថា ក្រសួង ស្ថាប័នអង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត នឹងចាត់វិធានការអនុវត្តរាល់សកម្មភាពដូចមានពីចំណុច ១.១ ដល់ចំណុច ១.៩ ឱ្យកាន់តែសកម្មថែមទៀត ។

**២. ការព្យាបាល ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖**

**២.១.** បន្តការងារសាងសង់ ការរៀបចំឲ្យមានគណៈគ្រប់គ្រង ការរៀបចំកម្មវិធី និងបទដ្ឋានពាក់ព័ន្ធនានា សម្រាប់មជ្ឈមណ្ឌលជាតិផ្ដល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ ដើម្បីអាចទទួលយកជនរងគ្រោះដោយសារគ្រឿងញៀនបាននាចុងឆ្នាំ២០១៩ ។ បន្តសហការពិភាក្សាជាមួយក្រសួងមហាផ្ទៃ អំពីគម្រោងសាងសង់មណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀននៅខេត្តពោធិសាត់ និងពិនិត្យលទ្ធភាពកសាងមជ្ឈមណ្ឌលព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនមួយកន្លែងសម្រាប់បណ្ដាខេត្តនៅភាគឦសានប្រទេស ។

**២.២.** បន្តជម្រុញការព្យាបាល និងស្ដារនីតិសម្បាទាអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍តាមរយៈសេវាសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀនរបស់ក្រសួងសុខាភិបាល និងជម្រុញការរៀបចំតម្លើងបញ្ជីឈ្មោះឃុំ/សង្កាត់ឲ្យបាន២៥% លើចំនួនឃុំ/សង្កាត់គោលដៅចំនួនជាង៤០០ ដែលបានបើកបម្រើសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

**២.៣.** បន្តរៀបចំផែនការ និងគោលនយោបាយជាតិសម្រាប់ការងារព្យាបាល ស្ដារនីតិសម្បទា និងការធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន រួមទាំងឯកសារគោលសំខាន់ៗ និងចាំបាច់នានា ដើម្បធានាថាការផ្ដល់សេវាព្យាបាល ស្ដារនីតិសម្បទា និងសមាហរណកម្មមានលក្ខណៈជាពហុវិស័យ មានលក្ខណៈជាប្រព័ន្ធ និងធានាបានការផ្ដល់សេវាប្រកបដោយគុណភាព ។ ទន្ទឹមនោះ បន្តធ្វើបច្ចុប្បន្នភាពលើទិន្នន័យអ្នកញៀគ្រឿងញៀនឱ្យបានសុក្រឹត ។

**២.៤.** បន្តការគាំទ្រឱ្យបានពេញលេញ ក្នុងការបញ្ជូនអ្នកញៀនគ្រឿងញៀនឱ្យទៅទទួលការព្យាបាល ផ្ដល់ការស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈ បំណិនជីវិត និងការធ្វើសមាហរណកម្ម ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ ៖**

**៣.១.** ជម្រុញអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ស្ដីពីគ្រឿងញៀនឲ្យកាន់តែមានប្រសិទ្ធភាព។

**៣.២.** បន្តពង្រឹង និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន(BLO) បន្តលើកកម្ពស់សមត្ថភាពជំនាញ

ដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន ក៏ដូចជាការពង្រឹងការអនុវត្តច្បាប់ដើម្បីគាំទ្រដល់កម្មវិធីកាត់បន្ថយគ្រោះថ្នាក់។

**៣.៣.** បន្តពង្រឹងប្រសិទ្ធភាពអនុវត្តច្បាប់ ដើម្បីបំផ្លាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀន ដោយសហការយ៉ាងជិតស្និទ្ធជាមួយអន្តរជាតិ បណ្តាប្រទេសក្នុងតំបន់ ពិសេសប្រទេសជិតខាង ដើម្បីទប់ស្កាត់ការហូរចូលឲ្យបានជាអតិបរមានូវគ្រឿងញៀនគ្រប់ប្រភេទ ទាំងនៅតាមព្រលានយន្តហោះ នៅតាមបញ្ញើប្រៃសណីយ៍ ពិសេសនៅតំបន់ព្រំដែនកម្ពុជា-ឡាវ ។ បន្តស្រាវជ្រាវ និងបង្រ្កាបករណីផលិតកែច្នៃគ្រឿងញៀន និងករណីដាំដុះរុក្ខជាតិញៀនកញ្ឆា។

**៣.៤.** បន្តពង្រឹងកិច្ចប្រតិបត្តិការបង្រ្កាបបទល្មើសគ្រឿងញៀន ជម្រុញបញ្ចប់ការធ្វើកិច្ចសន្យាសហការលុបបំបាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន នៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋានដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។

**៣.៥.** បន្តពង្រឹងសមត្ថភាព ឆន្ទៈ គុណធម៌ស្មោះត្រង់នឹងវិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់តាមទិសស្លោក កុំ៣ ១រាយការណ៍របស់ **សម្តេចក្រឡាហោម ស ខេង** គឺ ៖ ១-កុំឲ្យពាក់ព័ន្ធ ២-កុំលើកលែង ៣-កុំអន្តរាគមន៍ និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖**

**៤.១.** បង្កើនការគ្រប់គ្រងសារធាតុគីមីផ្សំគ្រឿងញៀន និងសារធាតុញៀនដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ។

**៤.២.** ជំរុញការរៀបចំបទបញ្ញត្តិនានា និងកសាងផែនការ ស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងបណ្តុះបណ្តាលជំនាញដល់ ស្ថាប័នអនុវត្តច្បាប់។

**៤.៣.** បន្តសម្របសម្រួល និងជម្រុញដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសុខាភិបាល រៀបចំវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាសម្រាប់ម្ចាស់ និងបុគ្គលិកគ្រប់គ្រងក្រុមហ៊ុន រោងចក្រ សហគ្រាស ដែលមានប្រតិបត្តិការពាក់ព័ន្ធនឹងសារធាតុគីមី ឲ្យមានការយល់ដឹងអំពីការគ្រប់គ្រងការប្រើប្រាស់ និងការរក្សាទុក ពិសេសយល់ដឹងអំពីការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ យកទៅសំយោគផលិតគ្រឿងញៀនខុសច្បាប់ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖**

**៥.១.** បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាងតាមគ្រប់រូបភាព ដើម្បីពង្រឹងយន្តការត្រួតពិនិត្យ និងទប់ស្កាត់ការចរាចរឆ្លងកាត់គ្រឿងញៀន តាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ។

**៥.២.** បន្តពង្រឹងយន្តការ និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ឡាវ កម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ដោយផ្អែកតាមអនុសាសន៍ណែនាំរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការឈរជើងនៅតាមច្រកទ្វារព្រំដែន ហើយការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យនេះ ត្រូវដំណើរការឱ្យស្របទៅនឹងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល។

**៥.៣.** ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន តាមគ្រប់យន្តការ ទាំងទ្វេភាគី ត្រីភាគី ពហុភាគី ដើម្បីទប់ស្កាត់ការហូរចូលគ្រឿងញៀននៅតាមព្រំដែន ពិសេសការកសាង **ភូមិ-ឃុំ/សង្កាត់ ស**

**គ្មានគ្រឿងញៀន** នៅតាមបណ្ដោយព្រំដែន ដែលភាគីកម្ពុជា ឡាវ ថៃ និងវៀតណាម បានឯកភាពគ្នាកន្លងមក ។ ចំពោះមុខស្នើខេត្ត-ក្រុងជាប់ព្រំដែន ត្រូវជ្រើសរើសឃុំ/សង្កាត់មួយក្នុងខេត្ត-ក្រុង ដើម្បីបង្កើតជាភូមិ ស គ្មានគ្រឿងញៀន។ ជាមួយនេះ ត្រូវបន្តសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិឲ្យមានការគាំទ្រការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្ដាប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖**

**៦.១.** បន្តបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ទាំងនៅក្នុងសកលលោក ក្នុងតំបន់ ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន ពិសេសពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូជាតិ-អន្តរជាតិ ដើម្បីស្វែងរកមូលនិធិគាំទ្រលើការងារព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ ។

**៦.២.** បន្តកៀរគរបណ្ដាប្រទេសផ្ដល់ជំនួយនិងដៃគូអភិវឌ្ឍន៍នានា ពិសេសអង្គការUNODC ដើម្បីគាំទ្រសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា តាមរយៈការអនុវត្តផែនការសកម្មភាពរបស់បណ្ដាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ ។

**៦.៣.** បន្តពង្រឹង និងពង្រីកការអនុវត្តកាតព្វកិច្ច ដែលមានចែងក្នុងកិច្ចព្រមព្រៀង និងអនុសញ្ញាអន្តរជាតិ ស្ដីពីគ្រឿងញៀន ព្រមទាំងបង្កើតកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិគ្រឿងញៀន។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

**៧.១.** ពង្រឹងយន្តការសេនាធិការ ដើម្បីអនុវត្តការដឹកនាំពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីជំរុញប្រសិទ្ធភាពការងារទទួលបានលទ្ធផលល្អប្រសើរ និងមាននិរន្តរភាពទាំងការងារតាមដានបូកសរុបរាយការណ៍ និងវាយតម្លៃសភាពការណ៍គ្រឿងញៀន ។ល។

**៧.២.** បន្តអនុវត្តគោលនយោបាយលើកទឹកចិត្តដល់អង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនរួមមាន ស្នាដៃលើការងារផ្សព្វផ្សាយអប់រំ ស្នាដៃការព្យាបាល និងស្ដារនីតិសម្បទា ស្នាដៃក្នុងការអនុវត្តច្បាប់ លើកទឹកចិត្តចំពោះអតីតអ្នកញៀនគ្រឿងញៀន ក្រុមគ្រួសារ និងសហគមន៍របស់គេ ក្នុងការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៤ ។

**៧.៣.** បន្តអនុវត្តគោលនយោបាយ និងលើកទឹកចិត្តដល់អង្គភាព បុគ្គលមានស្នាដៃពិតប្រាកដក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ រួមទាំងវិស័យឯកជន ។

**៧.៤.** ជំរុញការរៀបចំបញ្ចូលគណៈកម្មការសម្របសម្រួលការព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមឃុំ-សង្កាត់ ទៅក្នុងសមាសភាពគណៈកម្មការដឹកនាំ និងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពនៅគ្រប់លំដាប់ថ្នាក់ ។

**៧.៥.** ជំរុញបញ្ចប់ការងាររៀបចំផែនការជាតិ០៥ឆ្នាំ(២០១៩-២០២៣) ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីបានទទួលការអនុម័តពីរាជរដ្ឋាភិបាល ។

**៧.៦.** បន្តរៀបចំវគ្គបណ្ដុះបណ្ដាលច្បាប់ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មេឃុំ ចៅសង្កាត់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងមន្ត្រីទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងឃុំ/សង្កាត់ នៅទូទាំងប្រទេស ។

**៧.៧.** ជំរុញនីតិវិធីពិនិត្យសេចក្តីព្រាង វិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលតែងតែណែនាំ និងតម្រង់ទិសលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានដឹកនាំយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី១ លើកទី២ និងលើកទី៣ ទទួលបានជោគជ័យយ៉ាងធំធេងប្រកបដោយការទទួលខុសត្រូវ មានការគាំទ្រ និងវាយតម្លៃខ្ពស់ ពីសាធារណមតិជាតិ អន្តរជាតិ ក៏ដូចជាប្រជាពលរដ្ឋទូទៅ និងកំពុងបន្តដឹកនាំយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ ឈានឆ្ពោះទៅរកជោគជ័យក្នុងវិស័យប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា។

សូមថ្លែងអំណរគុណផងដែរ ដល់គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងមន្ត្រីរាជការក្រោមឱវាទ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ វិស័យសាសនា បុគ្គលពាក់ព័ន្ធ ក៏ដូចជាសមាគមសង្គ្រោះ និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការគាំទ្រ ការកសាងមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ និងនៅកន្លែងផ្សេងៗទៀតក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល។សូមអរគុណចំពោះដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន សប្បុរសជន សិល្បករ និងជាប្រជាពលរដ្ឋ ដែលបានរួមចំណែកជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការធ្វើឲ្យបានសម្រេចលទ្ធផលជាផ្លែផ្កាដូចមានក្នុងរបាយការណ៍នេះ ។

សំណូមពរ និងអំពាវនាវដល់ផ្នែកពាក់ព័ន្ធទាំងអស់ សូមបន្តចូលរួមចំណែកដល់ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៤ និងទិសដៅការងាររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៩ ដើម្បីនាំមកនូវលទ្ធផលកាន់តែល្អប្រសើរ ធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ថែរក្សាបាននូវសុខុមាលភាពសង្គម ។

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**នាយឧត្តមសេនីយ៍. កែ_គិមយ៉ាន**

**ចម្លងជូន** :

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
" ដើម្បីជូនជ្រាប "
-ក្រសួងសមាជិក អ.ជ.ប.គ.ញ.
-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ.
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត
-នាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ